ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០០៩ | តម្លៃ ១.៥០០៛

# ការបង្កើនប្រសិទ្ធភាព នៃការផ្ដល់សេវាផលិតកម្ម នៅជនបទកម្ពុជា*


ទីស្នាក់ការសមាគមកសិករផលិតគ្រាប់ពូជស្រូវ ក្នុងស្រុកសូត្រនិគម. ខេត្តសៀមរាប

## សេចក្ដីផ្ដើម

ប្រព័ន្ធផ្ដល់សេវាផលិតកម្មនៅជនបទ (Rural Productive Service Delivery Systems: RPSDS) នេះ ពួកអ្នកផ្គត់ផ្គង់បានរៀបចំឡើង ក្នុងគោលគំនិតធានាឱ្យផលិតផល និងសេវានានាត្រូវបានផលិត កែច្នៃ និងបញ្ចូលទីផ្សារ ដើម្បីឱ្យបានទៅដល់ដៃអតិថិជននៅទីបញ្ចប់ ។ គំនិតនេះពួកអ្នកផ្គត់ផ្គង់សេវា ទាំងខាងរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិលបានផ្ដួចផ្ដើមឡើងជាយូរឆ្នាំមកហើយ ។តាំងពីកម្ពុជាបានអនុវត្តរបបសេដ្ឋកិច្ចទីផ្សារនៅឆ្នាំ១៩៩៣មក មានវិស័យជាច្រើនបានផ្ដល់ជាសេវាផ្សេងៗ ប៉ុន្តែគេនៅមានការយល់ដឹងតិចតួចនៅឡើយពីប្រសិទ្ធភាពនៃ RPSDS នៅកម្ពុជា ។ ដូច្នេះត្រូវពិនិត្យមើលឡើងវិញពីប្រព័ន្ធទាំងនេះ ជាពិសេសបញ្ហានានាដែលរាំងស្ទះដល់ការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព ។

## ការសិក្សានេះគោលដៅជាសំខាន់:

- ធ្វើការវាយតម្លៃពីផលប៉ះពាល់ និងចីរភាពនៃ RPSDS ដែលបានជ្រើសរើសមួយចំនួន និងដែលបច្ចុប្បន្នកំពុងដំណើរការនៅកម្ពុជា ។
- កំណត់ពីឧបសគ្គ និងបញ្ហាប្រឈមផ្សេងៗ ដែលរាំងស្ទះដល់ ប្រសិទ្ធភាពនៃ RPSDS ។
- ផ្ដល់ជាអនុសាសន៍មួយចំនួនសំដៅកែលំអ RPSDS និងដាក់បញ្ចូលប្រព័ន្ធនេះទៅក្នុងកម្មវិធី ផែនការ យុទ្ធសាស្ត្រ និងនយោបាយតាមវិស័យ/ថ្នាក់ជាតិ ។

## ក្របខ័ណ្ឌ និងវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះវាយតម្លៃពីផលប៉ះពាល់ ចីរភាព ឧបសគ្គ បញ្ហាប្រឈម ចំណាប់អារម្មណ៍របស់កសិករពីយុទ្ធសាស្ត្រ និងគោលនយោបាយដែលរដ្ឋាភិបាលដាក់ចេញលើការងារកសិកម្ម ឥរិយាបថ និងការអនុវត្តជាក់ស្ដែងរបស់កសិករក្នុងការអភិវឌ្ឍអាជីវកម្ម ដំណើរការទីផ្សារកសិកម្ម និងការលើកទឹកចិត្តខាងទីផ្សារនៅក្នុងខេត្តចំនួនបី គឺខេត្តតាកែវ កំពង់ស្ពឺ និងសៀមរាប

## មាតិកា

ការបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាផលិតកម្ម
នៅជនបទកម្ពុជា ........................................................១
អ្នកលក់ដូរនៅផ្សារក្នុងទីរួមខេត្តកំពង់ចាមប្រកបមុខរបរលក់ដូរ
ដើម្បីចិញ្ចឹមជីវិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ .......................... ៦
អភិបាលកិច្ចមូលដ្ឋានលើធនធានទ្រព្យរួម:
ករណីសិក្សាពីធារាសាស្ត្រនៅកម្ពុជា ............................ ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស...................... ១៦
— ស្ថានភាពក្នុងប្រទេស ...................... ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ................................ ២៤

* អត្ថបទនេះ បានតាក់តែងឡើងដោយលោក នេត នាថ (អ្នកស្រាវជ្រាវ និងអតីតអ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍សង្គម) លោក គីម សុធន (អ្នកស្រាវជ្រាវ) និង បណ្ឌិត ថេង វុទ្ធី (អ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ) នៅវិទ្យាស្ថាន CDRI និងដោយមានការចូលរួមចំណែកពីសំណាក់ លោក ឈឹម ឈន់ (ជំនួយការស្រាវជ្រាវក្នុងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ) និង អ្នកស្រី ប៊ុន ដូរីណា (អ្នកសម្របសម្រួលការចុះសិក្សាដល់កន្លែង) នៅ CDRI ។ អត្ថបទនេះ ផ្អែកលើគំរោងមួយសិក្សាពីប្រធានបទដូចគ្នា និងទទួលមូលនិធិពី IFAD ដែល CDRI សូមអរគុណយ៉ាងជ្រាលជ្រៅ ។

ដែលបច្ចុប្បន្នមានអ្នកផ្ដល់សេវាចំនួន ៦ក្រុម កំពុងដំណើរការគឺ ១) សេវាចំរុះផ្ដល់ដោយក្រុមហ៊ុន AQIP ដែលផ្ដោតជាចំបងលើការផ្គត់ផ្គង់គ្រាប់ពូជ និងការគ្រប់គ្រងការខាតបង់នៅក្រោយពេលប្រមូលផល ២) ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មចំរុះ សេវាខាងហិរញ្ញវត្ថុ និងទីផ្សារ ផ្ដល់ដោយអង្គការ CEDAC និង ៣) សេវាផ្ដល់ដោយគំរោង ECOSORN លើផ្នែកផលិតកម្មកសិកម្មចំរុះ ហិរញ្ញវត្ថុ ទីផ្សារ និងសេវាខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៤) សេវាខាងផ្សព្វផ្សាយបច្ចេកទេស និងម៉ាឃីតទីង ផ្ដល់ដោយអង្គការស្រែខ្មែរ ៥) សេវាផ្ដល់ព័ត៌មានទីផ្សារកសិកម្ម ផ្ដល់ដោយគំរោង CAMIP និង ៦) សេវាហិរញ្ញវត្ថុផ្ដល់ដោយធនាគារ ACLEDA ។

ការសិក្សានេះបានប្រើវិធីសាស្ត្រសិក្សាឯកសារនៅការិយាល័យ និងការចុះអង្កេតដល់កន្លែង ។ ការសិក្សាឯកសារនៅការិយាល័យមានការពិនិត្យឡើងវិញ នូវព័ត៌មានមានស្រាប់ស្ដីពីគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល រីឯការចុះអង្កេតដល់កន្លែង បានប្រើបច្ចេកទេស ៣ យ៉ាង ដើម្បីប្រមូលយកព័ត៌មានដំបូង គឺមានការសង្កេតដោយផ្ទាល់តាមរយៈទស្សនកិច្ចដល់កន្លែង បទសម្ភាសស៊ីជម្រៅ និងការពិភាក្សាតាមក្រុមស្នូល(FGD) ។ការសម្ភាសបានធ្វើឡើង៦លើកជាមួយអ្នកផ្ដល់សម្ភាសន៍ចំនួន ៣២នាក់ មកពីក្រុមអ្នកផ្ដល់សេវាទាំង ៦ក្រុម ហើយ FGD បានធ្វើ ១១លើក នៅក្នុង ១០ភូមិ ។ ក្នុង FGD នីមួយៗ មានអ្នកចូលរួម ១០នាក់ជាមធ្យម ។ ជាលក្ខណៈបច្ចេកទេសវិញ ការសិក្សាបានប្រើវិធីសាស្ត្រខ្សែចង្វាក់កំណត់តម្លៃ វិធីសាស្ត្រខ្សែចង្វាក់ផ្គត់ផ្គង់ និងវិធីសាស្ត្រប្រព័ន្ធកសិកម្ម ដើម្បីវាយតម្លៃ និងវិភាគពីបញ្ហាផ្សេងៗ ។ អត្ថបទនេះបានរៀបចំឡើងតាមលំដាប់លំដោយដូចតទៅ: ការពិនិត្យត្រួសៗ ពីអ្នកផ្ដល់សេវា ផលប៉ះពាល់ និងចីរភាព ឧបសគ្គ និងបញ្ហាប្រឈម ចំណាប់អារម្មណ៍របស់កសិករ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ។

**ដែនកំណត់:** អ្នកផ្ដល់សេវាដែលបានជ្រើសយក និង FGD គឺជាគំរូតាងមួយតូចណាស់នៅក្នុងតែ ៣ខេត្ត ប៉ុណ្ណោះ ហើយសេវាដូចគ្នាដែលអ្នកផ្ដល់ដូចគ្នាបានផ្ដល់ក្នុងខេត្តផ្សេងៗទៀត គឺមិនអាចដាក់បញ្ចូលបានទេ ដោយសារកំហិតខាងធនធាន និងពេលវេលា ។ ក្នុងរយៈពេលសិក្សាសរុបចំនួន ៤៥ថ្ងៃ នៅខែមករា-មីនា ២០០៩ យើងអាចបែងចែកពេលវេលាបានត្រឹមតែ ១៤ថ្ងៃប៉ុណ្ណោះ សំរាប់ការចុះអង្កេតដល់កន្លែង ។ ដូច្នេះលទ្ធផលរកឃើញ ការពិភាក្សា និងសេចក្ដីសន្និដ្ឋាននៃការសិក្សានេះ គឺផ្អែកលើអ្នកផ្ដល់សេវា និងបណ្ដាខេត្តដែលបានជ្រើសយកមកសិក្សា ដូច្នេះអាចមិនគ្រប់គ្រាន់សំរាប់ធ្វើការសន្និដ្ឋានជាទូទៅទេ ។

## លទ្ធផលរកឃើញ

### អ្នកផ្ដល់សេវា

*ការពិនិត្យត្រួសៗ*

អង្គការស្រែខ្មែរ, ECOSORN, CEDAC និង AQIP មានផ្ដល់សេវាចំរុះជាច្រើន ប៉ុន្តែកំរិតចំរុះ និងលក្ខណៈសំគាល់នៃសេវាទាំងនោះ វាប្រែប្រួលខុសៗគ្នា ។ ECOSORN មានសេវាចំរុះ ៥យ៉ាង អង្គការស្រែខ្មែរ មានសេវាចំរុះ ៣យ៉ាង និង AQIP មានតែ ២យ៉ាង ប៉ុណ្ណោះ ។ អង្គការស្រែខ្មែរ, ECOSORN និង CEDAC ជាអង្គភាពមិនស្វែងរកចំណេញ រីឯ AQIP ជាអង្គភាពស្វែងរកចំណេញ ។ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដែលរួមមានប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ប្រព័ន្ធព័ត៌មានទីផ្សារ ការបង្កើតសមាគមផលិតករ និងការបណ្ដុះបណ្ដាលបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ ត្រូវបានផ្ដល់ទៅឱ្យកសិករគំរូដោយ ECOSORN ចំណែកឯអង្គការ CEDAC និងស្រែខ្មែរវិញ មិនមានបញ្ចូលនូវប្រព័ន្ធព័ត៌មានទីផ្សារ ឬការបណ្ដុះបណ្ដាលបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ទេ ប៉ុន្តែអង្គការទាំងនេះជួយកសិករក្នុងការបង្កើតជាក្រុមសន្សំប្រាក់ និងផ្ដល់ការបណ្ដុះបណ្ដាលពីគោលគំនិតសំខាន់ៗ នៃតំលៃបន្ថែមដូចជា ការជ្រើសរើសមុខដំណាំមានតំលៃខ្ពស់ទៅតាមរដូវកាល ជាក់លាក់ជាដើម ។

CEDAC មានបញ្ចូលការបណ្ដុះបណ្ដាលពីការបង្កើតសមាគមផលិតករ នៅក្នុងការផ្ដល់សេវារបស់ខ្លួន ប៉ុន្តែអង្គការស្រែខ្មែរមិនមានសេវានេះទេ ។ ក្រុមហ៊ុន AQIP បានបង្កើតជាសមាគមផលិតករមួយ ដើម្បីផ្គត់ផ្គង់ គ្រាប់ពូជទៅក្រុមហ៊ុន ។ ECOSORN ខុសប្លែកពីអង្គការ CEDAC ស្រែខ្មែរ និង AQIP គឺមិនមានផ្ដល់សេវាដោយផ្ទាល់ ដល់កសិករឡើយ ប៉ុន្តែបានចុះកិច្ចសន្យាម៉ៅការបន្តទៅឱ្យអ្នកផ្ដល់សេវា មានជំនាញឯកទេស ដើម្បីឱ្យគេផ្ដល់សេវាដ៏ជាក់លាក់ផ្សេងៗទៅដល់កសិករគំរូ និងតំបន់នៅក្នុងគំរោង ។ ECOSORN ធ្វើដូច្នេះ ព្រោះមិនមានបុគ្គលិក និងសមត្ថភាពគ្រប់គ្រាន់ដើម្បីផ្ដល់សេវាដោយផ្ទាល់ ។ ស្រដៀងគ្នានេះដែរ ដោយសារកង្វះដី និងបុគ្គលិកក្រុមហ៊ុន AQIP បានសម្របសម្រួលជាមួយសមាគមផលិតកររបស់ខ្លួន តាមរយៈការចុះកិច្ចសន្យាជាមួយសមាគម លើការផ្គត់ផ្គង់គ្រាប់ពូជក្នុងតម្លៃបានព្រមព្រៀងគ្នា ។ ជាការតបស្នង AQIP យល់ព្រមផ្ដល់ឧបត្ថម្ភធនឱ្យសមាគមតាមរយៈកំចីមិនគិតការប្រាក់សំរាប់ជី និងគ្រាប់ពូជ ។

អង្គការស្រែខ្មែរ និង CEDAC ផ្ដល់សេវាក្នុងទំរង់ត្រឹមជាការបណ្ដុះបណ្ដាលប៉ុណ្ណោះ គឺមិនមានប្រព័ន្ធសម្របសម្រួលជាក់លាក់ឡើយ ។ ACLEDA ជាធនាគារពាណិជ្ជ ដែលផ្ដល់តែសេវា ហិរញ្ញវត្ថុ រីឯ CAMIP ដែលជាគំរោងផ្ដល់មូលនិធិ ដោយអង្គការ CIDA និងរដ្ឋាភិបាលកម្ពុជានោះ មានផ្ដល់ត្រឹមព័ត៌មាន ពីទីផ្សារកសិកម្មប៉ុណ្ណោះ ។ ACLEDA បានបង្កើតតំលៃបន្ថែមសំរាប់អង្គភាពខ្លួនផ្ទាល់ និងបានបង្កើតគោលនយោបាយបទបញ្ជា និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដើម្បីសម្របសម្រួលការផ្ដល់សេវា ។ CAMIP ជាគំរោងសាធារណៈ មិនស្វែងរកចំណេញមួយដែលត្រូវដំណើរការ ៤ឆ្នាំ (២០០៦-២០០៩) ហើយមិនមានទាក់ទង ឬក៏បង្កើតនូវប្រព័ន្ធខ្សែចង្វាក់កំណត់តម្លៃអ្វីឡើយ ។ មុខងារចំបងរបស់ CAMIP គឺបញ្ជូនព័ត៌មានទីផ្សារកសិកម្មទៅឱ្យភាគីដែលចាប់អារម្មណ៍ ។ ការសម្របសម្រួលរវាង CAMIP និងអ្នកលក់ដុំ ដើម្បីទទួលបានព័ត៌មានពីថ្លៃលក់ដុំ និងអត្ថប្រយោជន៍ទៅវិញទៅមក គឺឈរលើមូលដ្ឋានស្ម័គ្រចិត្តជាសំខាន់ ។

## *ផលប៉ះពាល់ និងចីរភាព*

កសិករភាគច្រើន បានជ្រើសប្រើគ្រាប់ពូជដែលផ្ដល់ផលល្អ ប៉ុន្តែការទទួលយកប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) វាប្រែប្រួលខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ។ កសិករទាំងអស់ដែលមានកិច្ចព្រមព្រៀងជាមួយ AQIP ទទួលយក SRI ហើយ ២៥% នៃកសិករគំរូរបស់ CEDAC ទទួលយកប្រព័ន្ធនេះដែរ រីឯកសិករគំរូមួយភាគធំរបស់ ECOSORN និងអង្គការស្រែខ្មែរ ទំនងជាមិនទទួលយកប្រព័ន្ធនេះទេ ។ កសិករភាគច្រើនមិនចង់ទទួលយក SRI ពីព្រោះត្រូវប្រើពលកម្មច្រើន ។ កសិកររបស់ AQIP បានទទួលយក SRI ព្រោះត្រូវគោរពតាមកិច្ចសន្យា ។ស្រដៀងគ្នានេះដែរ ការជ្រើសប្រើវិធានការចំរុះថែទាំដំណាំ (IPM) ដោយកសិករគំរូក៏ប្រែប្រួលខុសគ្នា ព្រោះកសិករខ្លះយល់ថា ថ្នាំគីមីសំលាប់សត្វល្អិតវាមានប្រសិទ្ធភាពជាងថ្នាំសំលាប់សត្វល្អិតតាមបែបធម្មជាតិ ។ ទោះយ៉ាងនេះក្ដី កសិករភាគច្រើនរាយការណ៍ថា គ្រាប់ពូជគុណភាពខ្ពស់ ប្រព័ន្ធ SRI វិធានការចំរុះថែទាំដំណាំ និងការប្រើជីកំប៉ុស បានបង្កើនផលិតភាពនិងតំលៃបន្ថែម ។កសិករជាប់កិច្ចសន្យាជាមួយ AQIP បានផ្លាស់ប្ដូរពីផលិតកម្មស្រូវសំរាប់មួយរស់ ទៅជាផលិតកម្មស្រូវសំរាប់ពាណិជ្ជកម្ម ។ កសិករនានា បានយល់ដឹងកាន់តែប្រសើរពីគោលការណ៍អាជីវកម្មស្រូវពូជ ដូចជាតំរូវការរបស់អ្នកប្រើប្រាស់លើគ្រាប់ពូជគុណភាពខ្ពស់ជាដើម ។ ធនាគារ ACLEDA បានបង្កើនការផ្ដល់កំចីក្នុងវិស័យកសិកម្មទាំងអស់ ពី ១១% នៃការផ្ដល់កំចីសរុបនៅឆ្នាំ២០០៧ ដល់ ១៤% នៅឆ្នាំ២០០៨ (៥៤% នៃទឹកប្រាក់កំចីសរុប ខាងកសិកម្ម គឺសំរាប់ផលិតកម្មដំណាំ) ។ ដោយសារការផ្ដល់កំចីឱ្យនេះ (អាចមានកត្តារួមចំណែកក្រៅពីនេះទៀត) សហគ្រាសធុនតូច និងមធ្យម អាចធ្វើវិនិយោគជាម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនបូមទឹក សំរាប់ដាំបន្លែ និងម៉ាស៊ីនកិនស្រូវ ។ល។ ដែលជួយសំរួលដល់ការទទួលយកបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតថ្មីៗ ។ គេមិនដឹងច្បាស់ទេថា តើសេវាព័ត៌មានទីផ្សារកសិកម្មដែល CAMIP ផ្ដល់ឱ្យក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅនេះ បានចូលរួមចំណែកប៉ុណ្ណា ក្នុងការលើកស្ទួយសហគ្រាសកសិកម្ម ពីព្រោះកសិករ និងផលិតករភាគច្រើនបានរាយការណ៍ថា ព័ត៌មានផ្ដល់ដោយសេវានោះ ច្រើនតែចាស់ហួសពេល ហើយការបណ្ដុះបណ្ដាលផ្ដល់ដោយសាលាម៉ាឃីទីងសំរាប់កសិករ ក៏មិនសូវមានប្រយោជន៍ដែរ (FGD ថ្ងៃទី ២-៤ កុម្ភៈ ២០០៩) ។

ចីរភាពសេវាកម្ម ផ្អែកលើលក្ខណៈបែបបទ និងវិធីសាស្ត្រនៃការផ្ដល់សេវា ។ សេវាចំរុះរបស់ AQIP ទំនងជានឹងបន្តទៅមុខ ពីព្រោះគំរោងនេះអាចរស់រានបានខាងហិរញ្ញវត្ថុ ហើយពួកកសិករជាប់កិច្ចសន្យាបានទទួលផលចំណេញជាកំណើនប្រាក់ចំណូល និងចំណេះដឹង ។ ប៉ុន្តែកំរិតដែលកសិករទទួលយកបច្ចេកវិទ្យា និងសេវារបស់ អង្គការស្រែខ្មែរ ECOSORN និងអាចរបស់ CEDAC និង CAMIP ផងដែរ គឺមិនទាន់ឡើងដល់កំរិតមួយ ដែលអាចធានាថា កសិករគំរូនឹងបន្តប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនោះឡើយ ។ កសិករក្រីក្រ ដែលរកមួយថ្ងៃហូបមួយថ្ងៃ ត្រូវការជំនួយបច្ចេកទេស និងហិរញ្ញវត្ថុឱ្យបានច្រើន និងមាន រយៈពេលវែងជាងនេះទៀត ។ ទោះបីជា ECOSORN និងអង្គការស្រែខ្មែរ បានដាក់បញ្ចូលបុគ្គលិកផ្សព្វផ្សាយបច្ចេកទេសមកពីមន្ទីរកសិកម្មខេត្ត និងបានបណ្ដុះបណ្ដាល អ្នកបណ្ដុះបណ្ដាលដើម្បីឱ្យពួកគេបន្តផ្ដល់សេវា ក្រោយពេលអង្គការបញ្ចប់ការងារក្នុងប៉ុន្មានឆ្នាំខាងមុខក្ដី ក៏បុគ្គលិក និងអ្នកបណ្ដុះបណ្ដាលទាំងនោះ មិនទំនងជានឹងបន្តផ្ដល់សេវាឡើយ ព្រោះមិនទាន់ឃើញមានបង្កើតគ្រឿងលើកទឹកចិត្តជាក់លាក់ណាមួយនៅឡើយ (Danish Agricultural Advisory Service ២០០៨ និង FGDs កាលពីថ្ងៃទី ៥ កុម្ភៈ ២០០៩) ។ ធនាគារ ACLEDA ទំនងជាបន្តផ្ដល់សេវាហិរញ្ញវត្ថុចំពោះវិស័យកសិកម្ម បើសិនជាមានចីរភាពខាងហិរញ្ញវត្ថុ ។ ធនាគារនេះ បានផ្ដល់ហិរញ្ញប្បទានដល់វិស័យកសិកម្មអស់រយៈពេលជិត ២ទសវត្សរ៍ មកហើយ ។ សេវាផ្ដល់ព័ត៌មានទីផ្សារកសិកម្ម ទំនងជាមិនអាចបន្តផ្ដល់ព័ត៌មានប្រកបដោយគុណភាពទៀតឡើយ នៅពេលគំរោង CAMIP ត្រូវបញ្ចប់ក្នុងឆ្នាំ២០០៩ ពីព្រោះការិយាល័យទីផ្សារកសិកម្ម (AMO) ខ្វះខាតធនធានសំរាប់បន្តសេវានេះ ។

## *ឧបសគ្គ និងបញ្ហាប្រឈម*

កង្វះមូលធន កង្វះបុគ្គលិកមានសមត្ថភាពគ្រប់គ្រាន់ ការផ្លាស់ប្ដូរបុគ្គលិកមានអត្រាខ្ពស់ កសិករមានកំរិតអប់រំទាប ភាពក្រីក្រ កង្វះទឹកនៅរដូវប្រាំង ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងគ្រឿងសម្របសម្រួលទីផ្សារ) កង្វះបច្ចេកទេស និងការផ្សព្វផ្សាយបច្ចេកទេសកសិអាជីវកម្មសំរាប់ជួយទ្រទ្រង់មានមិនគ្រប់គ្រាន់ និងកង្វះការចុះបញ្ជីដីធ្លី គឺជាឧបសគ្គ និងបញ្ហាប្រឈមជាទូទៅ ដែលរារាំងដល់ពួកអ្នកផ្ដល់សេវា និងការលើកស្ទួយសហគ្រាសកសិកម្ម ។ ក្រៅពីបញ្ហាខាងលើ ការលំបាកក្នុងការស្វែងរកអ្នកម៉ៅការដែលមានសមត្ថភាព និងការលំបាកក្នុងការគ្រប់គ្រង និងសម្របសម្រួលជាមួយអ្នកម៉ៅការ បានធ្វើឱ្យ ECOSORN ត្រូវពន្យារពេលអនុវត្តគំរោងនៅក្នុងភូមិជាច្រើនខែ ។ អង្គការស្រែខ្មែរ CEDAC និង CAMIP ខ្វះខាតបុគ្គលិកមានសមត្ថភាពល្អ និងមានជំនាញឯកទេសក្នុងការអភិវឌ្ឍអាជីវកម្ម ហើយក៏មិនអាចជួយដល់កសិករ និងសមាគមផលិតករក្នុងការអភិវឌ្ឍអាជីវកម្មបាន ។ ដោយសារកង្វះបុគ្គលិក និងសមត្ថភាពមានកំរិតខាងការអភិវឌ្ឍអាជីវកម្ម សាលាម៉ាឃីទីងសំរាប់កសិករ ដែលដំណើរការដោយ CAMIP មិនមានភាពទាក់ទាញចំពោះកសិករ និងពាណិជ្ជករឡើយ ។

ការរារែករបស់កសិករក្នុងការទទួលយកប្រព័ន្ធ SRI និងកង្វះការផ្គត់ផ្គង់ គឺជាបញ្ហាប្រឈមទូទៅចំពោះអ្នកផ្ដល់សេវាគ្រប់ៗគ្នា ។ កង្វះលទ្ធភាពក្នុងការផលិតគ្រាប់ពូជ និងផ្ដល់ហិរញ្ញប្បទានដល់កសិករជាប់កិច្ចសន្យា កំពុងចោទបញ្ហាដល់ខ្សែចង្វាក់កំណត់តំលៃរបស់ AQIP ។ កង្វះបុគ្គលិកជំនាញខាងគ្រប់គ្រងអាជីវកម្ម សំរាប់ជួយជ្រោមជ្រែងដល់ហាងលក់ផលិតផលសរីរាង្គរបស់សហគមន៍ និងសមាគមផលិតករ កំពុងចោទបញ្ហាថែមទៀតដល់ CEDAC ។ សព្វថ្ងៃពួកអតិថិជន ក៏មិនទាន់ពេញចិត្តបង់ថ្លៃខ្ពស់ជាងសំរាប់ផលិតផលសរីរាង្គនៅឡើយ (FGDs ថ្ងៃទី ២-៤ កុម្ភៈ និងសម្ភាសន៍ ថ្ងៃទី ១០ កុម្ភៈ ២០០៩) ។ បញ្ហានេះបានរាំងស្ទះដល់ការជំរុញផលិតផលសរីរាង្គ ។ភាពលំបាកនឹងទទួលបានសេវាហិរញ្ញវត្ថុ (ការប្រាក់ខ្ពស់)

និងព័ត៌មានទីផ្សារចាស់ហួសពេល នៅតែជាបញ្ហាប្រឈមចំបង សំរាប់ ACLEDA និង CAMIP ហើយវាបន្តគំរាមកំហែងដល់ការជំរុញសហគ្រាសកសិកម្ម ។ លើសពីនេះទៀត ដោយហេតុថាវិធីសាស្ត្រមួយផ្នែករបស់ CAMIP គឺការផ្សព្វផ្សាយ និងលើកកម្ពស់សមត្ថភាពកសិករ និងពាណិជ្ជករក្នុងមូលដ្ឋាន ដូច្នេះការចូលរួមកំរិតទាបរបស់ពួកគេ នៅក្នុងកម្មវិធីសាលាម៉ាឃីទីងសំរាប់កសិករ បានរាំងស្ទះដល់ការកសាងសមត្ថភាព និងការប្រើប្រាស់ព័ត៌មាន ។

## ចំណាប់អារម្មណ៍របស់កសិករ

### គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម

ក្រុមគ្រួសារភាគច្រើនមានដីតិចតួច ហើយនៅភូមិភាគច្រើនពុំមានទឹកស្រោចស្រពពេញៗមួយឆ្នាំទេ ។ កសិករនៅភូមិទាំងនោះ ត្រូវចំណាយច្រើនលើធាតុចូល (ជី គ្រាប់ពូជ និងសាំងជាដើម) ហើយត្រូវប្រឈមមុខនឹងអត្រាសត្វចិញ្ចឹមឈឺ និងងាប់ក្នុងកំរិតខ្ពស់ គួបផ្សំនឹងកង្វះការជ្រើសរើសបង្កាត់ពូជសត្វទៀតផង ។ កសិករភាគច្រើនយល់ថា បញ្ហាទាំងនេះជាឧបសគ្គចំបងៗ ដែលរារាំងដល់គោលនយោបាយរបស់រដ្ឋាភិបាល ស្តីពីការធ្វើពិពិធកម្មសន្តិសុខស្បៀង និងការបង្កើនផលិតភាព ។ កសិករភាគច្រើនយល់ឃើញថាបុគ្គលិកដែលមានសមត្ថភាពមិនគ្រប់គ្រាន់ និងសន្ទុះចិត្តខ្សោយ បានចោទជាបញ្ហាចំពោះគោលនយោបាយតាមវិស័យស្តីពីការពង្រីង និងកែលំអការស្រាវជ្រាវខាងកសិកម្ម និងធ្វើឱ្យទន់ខ្សោយដល់ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ន និងការបង្កើតច្បាប់សំរាប់ប្រព័ន្ធផ្តល់សេវាផលិតកម្មនៅជនបទ ។ ការទទួលបានព័ត៌មានមិនស្មើគ្នាក្នុងចំណោមកសិករ និងប្រព័ន្ធចែកចាយផលិតផលគ្មានប្រសិទ្ធភាពនៅតាមតំបន់សិក្សាភាគច្រើន បានធ្វើឱ្យកសិករ និងពាណិជ្ជករភាគច្រើននៅតាមមូលដ្ឋានជឿថា គោលនយោបាយស្តីពីច្រកទីផ្សារសំរាប់ផលិតផលកសិកម្មទំនងមិនបានជោគជ័យឡើយ ។ ភាពយឺតយ៉ាវនៃការចុះបញ្ជីដីធ្លី និងកំណើនជម្លោះដីធ្លី ក៏បង្កឧបសគ្គដល់គោលនយោបាយស្តីពីការកាន់កាប់ដី ការអភិវឌ្ឍទីផ្សារដីធ្លី និងការប្រើប្រាស់ដីអំណោយផលដល់អ្នកក្រផងដែរ ។ ជាលទ្ធផល ក្រុមគ្រួសារភាគច្រើនមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ខ្លួនទេដែលធ្វើឱ្យអ្នកក្រីក្រភាគច្រើនមិនអាចទទួលបានឥណទាន ។

### របៀបរបបអនុវត្ត និងឥរិយាបទរបស់កសិករក្នុងការធ្វើអាជីវកម្ម

កសិករភាគច្រើនយល់ថា ដី ទឹក និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មជាកត្តាសំខាន់បំផុត សំរាប់ការដោះស្រាយស្បៀងអាហារក្នុងគ្រួសារ រីឯហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រព័ន្ធព័ត៌មានទីផ្សារ សេវាគាំទ្រខាងកសិអាជីវកម្ម និងលទ្ធភាពទទួលបានឥណទាន និងបច្ចេកវិទ្យា គឺជាកត្តាសំខាន់បំផុតដើម្បីបង្កើនផលិតកម្មសំរាប់លក់ ។

### គ្រឿងលើកទឹកចិត្តទីផ្សារ

កង្វះការគាំទ្រជាធាតុចូលកសិកម្ម និងការគាំទ្រខាងអាជីវកម្ម ថ្លៃប្រេងខ្ពស់ ថ្លៃជីខ្ពស់ កង្វះការពេញចិត្តពីអតិថិជនលើការបង់ថ្លៃបន្ថែមសំរាប់ផលិតផលសរីរាង្គ តំរូវការទាបនូវផលិតផលកសិកម្មក្នុងស្រុក និងអត្រាការប្រាក់ខ្ពស់នៅតាមធនាគារ និងស្ថាប័នហិរញ្ញវត្ថុខ្នាតតូច (MFIs) គឺជាឧបសគ្គចំបងៗចំពោះកសិករក្នុងការឆ្លើយតបនឹងតម្រូវការទីផ្សារ ។ នៅឆ្នាំ២០០៨ ជីគីមីលក់ថ្លៃ ១៦០.០០០រៀល/បាវ ធៀបនឹង ៦០.០០០រៀល/បាវ កាលពីឆ្នាំ២០០៥ (AMO 2005; AMO 2008) ។ ថ្លៃប្រេងក៏មាននិន្នាការស្រដៀងគ្នានេះ ។ ការគាំទ្រខាងអាជីវកម្ម ក៏មិនមានផ្តល់ឱ្យកសិករដែរ ។ ទើបតែថ្មីៗនេះទេ ដែលគេបានណែនាំបង្ហាញដល់កសិករពីខ្សែចង្វាក់កំណត់តំលៃ និងតំលៃបន្ថែម តាមរយៈការបណ្តុះបណ្តាលនៅតាមភូមិជ្រើសរើសមួយចំនួន ប៉ុន្តែនៅមានភូមិភាគច្រើនណាស់ ដែលមិនទាន់ទទួលបានការណែនាំឬការគាំទ្រតាមរូបភាពនេះ ។ លទ្ធផលរកឃើញក្នុងការសិក្សានេះ (FGD ហាងលក់ផលិតផលសរីរាង្គរបស់សហគមន៍តាមការណែនាំរបស់ CEDAC នៅខេត្តតាកែវ និងការសម្ភាសជាមួយអតិថិជន កាលពីថ្ងៃទី ២-៤ កុម្ភៈ ២០០៩) និងការសិក្សារបស់ក្រុមហ៊ុន Agrifood Consulting International and CamConsult (2006) បានបង្ហាញថា អតិថិជននៅមិនទាន់ពេញចិត្តបង់ថ្លៃបន្ថែមសំរាប់ផលិតផលកសិកម្មសរីរាង្គទេ ។ ថ្លៃប្រេងខ្ពស់ ថ្លៃជីខ្ពស់ និងអវត្តមានការគាំទ្រជាធាតុចូលកសិកម្ម ធ្វើឱ្យកសិករមើលមិនឃើញពីផលចំណេញក្នុងការឆ្លើយតបនឹងតំរូវការទីផ្សារ ។ មានតែកសិករមួយភាគតូច ដែលគេអញ្ជើញឱ្យចូលរួមក្នុងគំរោងសាកល្បងនោះទេ ដែលទទួលបានការគាំទ្រជាធាតុចូល ហើយជំនួយគាំទ្រនេះ គឺសំរាប់តែការងារធ្វើបង្ហាញឱ្យឃើញជាក់ស្តែងប៉ុណ្ណោះ ។

### ដំណើរការនៃទីផ្សារកសិកម្ម

ការត្អូញត្អែរចំបងៗរបស់កសិករភាគច្រើនស្តីពីដំណើរការទីផ្សារ រួមមានពាណិជ្ជករនៅក្នុងភូមិនីមួយៗមានតិចនាក់ពេក (១នាក់ ទៅ ៣នាក់) ពាណិជ្ជករឱ្យថ្លៃទាបជាងថ្លៃផ្សព្វផ្សាយតាមវិទ្យុ ការទទួលបានព័ត៌មានមិនស្មើគ្នាអំពីថ្លៃទំនិញនិងទីផ្សារ ផលិតផលក្នុងស្រុកមិនសូវមានលក្ខណៈប្រកួតប្រជែង និងការឡើងចុះខ្លាំងនៃថ្លៃផលិតផល ។ កសិករភាគច្រើនជឿថាដំណើរការទីផ្សារកសិកម្មបច្ចុប្បន្ន មានលក្ខណៈមិនសូវល្អដោយសារតែព័ត៌មានទទួលបានមិនស្មើគ្នា ។ ភាពមិនស្មើគ្នានេះ បណ្តាលមកពីការដឹកជញ្ជូន និងការទទួលបានព័ត៌មាន មានតំលៃខ្ពស់ពេក ។ Higgins (2009) បានរាយការណ៍ថា ចំណាយដឹកជញ្ជូននៅកម្ពុជាថ្លៃលើសនៅថៃស្មើរដល់ ៣,៧៥ដង[1] ហើយថ្នល់ក្រាលកៅស៊ូនៅកម្ពុជាមាន ៥% ធៀបនឹង ៩៨% នៅថៃ ។ មានតែពាណិជ្ជករ និងអ្នកលក់ដុំមួយចំនួនដែលក្តាប់ព័ត៌មានទីផ្សារបានល្អប៉ុណ្ណោះ ដែលទទួលបានផលចំណេញ ដូច្នេះពួកគេមិនចង់ឱ្យថ្លៃខ្ពស់សមរម្យដល់កសិករឡើយ ។ CAMIP បានធ្វើការផ្សព្វផ្សាយពីថ្លៃទំនិញលើទីផ្សារតាមរយៈវិទ្យុ ទូរស័ព្ទ វែបសាយ និងការបោះពុម្ពផ្សាយផ្សេងៗនៅតាម ១១ ខេត្តក្រុង ដែលមានទាំងខេត្តសៀមរាប និងតាកែវ ប៉ុន្តែព័ត៌មាននេះ នៅតែមិនបានទៅដល់កសិករភាគច្រើន ដោយ

---

១ ១៥ដុល្លារ/តោន ក្នុងចំងាយផ្លូវ ១០០គីឡូម៉ែត្រ នៅកម្ពុជា ធៀបនឹង ៧ដុល្លារ នៅវៀតណាម និង ៤ដុល្លារ នៅថៃ (Higgins, ២០០៩)

សារតែកង្វះចំណាប់អារម្មណ៍ពីសេវា ភាពស្មុគស្មាញខាងបច្ចេកទេស ភាពចាស់ហួសពេលនៃព័ត៌មាន និងកង្វះឧបករណ៍ទទួលព័ត៌មាន ។ ព័ត៌មានចាស់ហួសពេល ពីព្រោះ CAMIP ធ្វើការប្រមូលវារៀងរាល់បីថ្ងៃម្តងប៉ុណ្ណោះ ។ កសិករភាគច្រើននិយាយថា ទីផ្សារប្រហែលនឹងមានដំណើរការប្រសើរឡើង ប្រសិនបើពាណិជ្ជករ និងអ្នកលក់ដុំមានចំនួនកាន់តែច្រើន ហើយការទទួលបានព័ត៌មាន វាមានតំលៃទាបជាងនេះ ។

## សន្និដ្ឋាន

ការសិក្សាលើអ្នកផ្តល់សេវាទាំង ៦ ក្រុម បានបង្ហាញពីបែបបទផ្តល់សេវាពីរប្រភេទ ។ ACLEDA និង CAMIP ផ្តល់សេវាទោល រីឯអង្គការស្រែខ្មែរ ECOSORN, CEDAC និង AQIP ផ្តល់សេវាចំរុះ ។ ផលប៉ះពាល់ និងចីរភាពនៃសេវាទាំងនោះ ផ្អែកលើលក្ខណៈផ្ទាល់ និងវិធីសាស្ត្រផ្គត់ផ្គង់របស់អ្នកផ្គត់ផ្គង់សេវា ។ ឧបសគ្គ និងបញ្ហាប្រឈមចំបងៗ ចំពោះយុទ្ធសាស្ត្រ និងគោលនយោបាយខាងកសិកម្មរបស់រដ្ឋាភិបាល រួមមានកង្វះខាត ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បច្ចេកទេស/ការផ្សព្វផ្សាយបច្ចេកទេស ព័ត៌មានទីផ្សារ ការគាំទ្រជាសេវាកសិអាជីវកម្ម ដីដាំដុះ ទឹក សេវាហិរញ្ញវត្ថុ ការគាំទ្រជាធាតុចូលកសិកម្ម ការអប់រំ គួបផ្សំនឹងភាពក្រីក្រខ្លាំងនៃគ្រួសារកសិករ ថ្លៃប្រេងខ្ពស់ និងថ្លៃជីខ្ពស់ ។ បញ្ហាទាំងនោះបានរាំងស្ទះផងដែរ ដល់សហគ្រាសកសិកម្ម ការឆ្លើយតបរបស់កសិករចំពោះគ្រឿងលើកទឹកចិត្តទីផ្សារ និងចំណាប់អារម្មណ៍របស់កសិករ អំពីដំណើរការទីផ្សារកសិកម្ម ហើយក៏ក្លាយជាឧបសគ្គចំពោះការផ្តល់សេវាផលិតកម្មនៅជនបទប្រកបដោយប្រសិទ្ធភាព ។

## អនុសាសន៍

- ទោះបីគេយល់ថា ហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលពីការគ្រប់គ្រង លំហូរសាច់ប្រាក់មានសារៈសំខាន់បំផុត សំរាប់បង្កើនលទ្ធភាពរបស់កសិករ ដើម្បីទទួលបានសេវាហិរញ្ញវត្ថុក្តី ក៏អត្រាការប្រាក់ខ្ពស់របស់ធនាគារនៅរាំងស្ទះដំណើរការនេះដដែល ។ ដូច្នេះចាំបាច់ត្រូវបញ្ចុះអត្រាការប្រាក់ឱ្យនៅទាបជាង ៣% ក្នុង ១ខែ និងត្រូវផ្តល់ការគាំទ្រខាងអាជីវកម្ម ។
- កសិករកំពុងចាប់ផ្តើមពេញចិត្តនឹងគ្រាប់ពូជមានគុណភាពខ្ពស់ហើយ ប៉ុន្តែក្រោយបានថ្លឹងថ្លែងពីតម្លៃគ្រាប់ពូជទាំងនេះ កសិករភាគច្រើនក៏សំរេចចិត្តបន្តប្រើប្រាស់គ្រាប់ពូជធម្មតាដដែល ។ ដូច្នេះគួរពិចារណាផ្តល់ឧបត្ថម្ភធនជួយចេញថ្លៃឱ្យគ្រួសារកសិករក្រីក្រ ដើម្បីឱ្យពួកគេមានលទ្ធភាពទិញគ្រាប់ពូជមានគុណភាពល្អ ។
- គួរមានបង្កើតវិទ្យុសាធារណៈមួយ ដែលអាចផ្សព្វផ្សាយពីថ្លៃផលិតផលដល់គ្រប់ៗគ្នានៅក្នុងភូមិ និងគួរកែលំអសាលាម៉ាឃីទីងសំរាប់កសិករ ដើម្បីបង្កើនការចូលរៀនដោយកសិករ និងពាណិជ្ជករមូលដ្ឋាន ។
- ការស្រាវជ្រាវដោយមានការចូលរួម ត្រូវបានណែនាំឱ្យប្រើហើយ ប៉ុន្តែជាទូទៅវិធីសាស្ត្រនេះ មិនទាន់បានអនុវត្តទូលំទូលាយឡើយនៅតាមភូមិភាគច្រើន ក៏ដូចជានៅមានកង្វះខាតការតាមដានបន្ត និងការបន្តលើកទឹកចិត្ត ។ម្យ៉ាងទៀតសមត្ថភាពអ្នកផ្សព្វផ្សាយបច្ចេកទេសក៏នៅមានកំរិតដែរ ។ ដូច្នេះត្រូវពង្រឹងសមត្ថភាព អ្នកទាំងនេះ និងការជំរុញការស្រាវជ្រាវដោយមានការចូលរួមឱ្យបាន កាន់តែទូលំទូលាយ ដើម្បីបង្កើនការផ្ទេរ និងការទទួលយកបច្ចេកវិទ្យា ។
- សេវាអភិវឌ្ឍន៍ជនបទចំរុះរបស់ECOSORN ហាក់ដូចជាសក្តិសមសំរាប់តំបន់ជនបទភាគច្រើននៅកម្ពុជា ប៉ុន្តែសេវានេះមានភាពស្មុគស្មាញ ពិបាកគ្រប់គ្រង និងងាយនឹងរងនូវហានិភ័យ ដូចជាការអនុវត្តយឺតយូរជាដើម ។ ដូច្នេះពីដំបូងគួរដាក់បញ្ចូលសេវាតែមួយចំនួនតូច បន្ទាប់មកទើបបង្កើនចំនួនសេវាជាបន្តបន្ទាប់ ។
- ក្នុងកម្មវិធីកំណែទម្រង់កម្មសិទ្ធិដីធ្លី គួរមានបង្កើតក្របខ័ណ្ឌមួយសំរាប់អនុវត្តច្បាប់ភូមិបាលឱ្យបានឆាប់តាមអាចធ្វើបាន ដើម្បីអាចពន្លឿនដល់កម្មវិធីការប្រើប្រាស់ដីអំណោយផលដល់ជនក្រីក្រ ការចុះបញ្ជីដីធ្លី និងការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី ។
- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសាធារណៈ គួរសាងសង់ជួសជុលឱ្យបានកាន់តែច្រើន ដើម្បីជួយសម្រួលផលិតកម្ម បង្កើនពាណិជ្ជកម្មរវាងតំបន់ជនបទ និងទីក្រុង និងត្រៀមទប់ទល់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់ ។
- គួរគិតគូរពិចារណាផ្តល់ឧបត្ថម្ភធនលើធាតុចូលដែលចាំបាច់សំរាប់កសិកម្ម ជាពិសេសនៅពេលមានវិបត្តិថ្លៃប្រេង និងជីកសិកម្ម ។

## ឯកសារយោង

Agrifood Consulting International and CamConsult (2006), Diagnostic Study, Phase 1 of Design, Agricultural Program, Cambodia, 2007-— Program Concept Document Final Report. Prepared for AusAID by Agrifood Consulting International (Bethesda, Maryland)

AMO (2008), *Agricultural Market Information Bulletin,* Monthly Report December 2008 (Agricultural Marketing Office, Ministry of Agriculture, Forestry and Fisheries) http://www.camis-kh.org/?q=en/node/79

AMO (2005), *Agricultural Market Information Bulletin,* Yearly Report 2005 (Agricultural Marketing Office, Ministry of Agriculture, Forestry and Fisheries) http://www.camis-kh.org/?q=en/node/79

Danish Agricultural Advisory Service (2008), *Mid Term Evaluation of Project KHM/AIDCO/2004/16793*—Draft Final Report (Delegation of the European Commission in Cambodia and ECOSRN in Cambodia)

Higgins, Stephen (2009), *Manufacturing and Infrastructure—Cambodia's Hidden Opportunity,* presentation to the Outlook Conference held in Phnom Penh on12 March 2009

# អ្នកលក់ដូរនៅផ្សារក្នុងទីរួមខេត្តកំពង់ចាមប្រកបមុខរបរលក់ដូរ ដើម្បីចិញ្ចឹមជីវិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ*

## សេចក្ដីផ្ដើម

ដោយមានការកសាងស្ពានគីហ្សុណាឆ្លងកាត់ទន្លេមេគង្គ ការជួសជុលផ្លូវជាច្រើនខ្សែដែលតភ្ជាប់ទៅតំបន់ភាគខាងជើង និងភាគឦសាន ក៏មានសកម្មភាពទីផ្សារកាន់តែមមាញឹកនៅទូទាំងប្រទេសកម្ពុជា ហើយទីរួមខេត្តកំពង់ចាមបានក្លាយទៅជាចំនុចប្រសព្វនៃប្រព័ន្ធដឹកជញ្ជូន និងសកម្មភាពពាណិជ្ជកម្មផ្សេងៗ ។ កំណើនសកម្មភាពទីផ្សារយ៉ាងឆាប់រហ័សបានផ្ដល់ឱកាសដល់ប្រជាជន ជាពិសេសស្ត្រី ក្នុងការរកប្រាក់ចំណូលតាមរយៈការលក់បន្លែ ផ្លែឈើ និងត្រី ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ផ្អែកលើការស្រាវជ្រាវនាពេលថ្មីៗ អត្ថបទនេះ រៀបរាប់ដោយសង្ខេបពីលក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការពិភាក្សាពីវិធីសាស្ត្រស្រាវជ្រាវ និងលទ្ធផលស្រាវជ្រាវសំខាន់ៗ[1] ។

## ការស្វែងយល់ពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ

តាមនិយមន័យទូលាយ សេដ្ឋកិច្ចក្រៅប្រព័ន្ធគឺជា សេដ្ឋកិច្ចទីផ្សារមួយចំណែកដែលមានលក្ខណៈមិនរៀបរយ មិនទាន់មានច្បាប់គ្រប់គ្រងល្អ ហើយធ្វើការផលិតទំនិញ និងសេវាសំរាប់លក់ រឺសំរាប់ធ្វើការទូទាត់ផ្សេងៗ ។ ដូច្នេះ ពាក្យ "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" សំដៅដល់សកម្មភាពសេដ្ឋកិច្ចទាំងអស់របស់បណ្ដាពលករ និងអង្គភាពសេដ្ឋកិច្ចដែលពុំមាន រឺមានមិនគ្រប់គ្រាន់នូវរបៀបរបបជាផ្លូវការផ្សេងៗសំរាប់គ្រប់គ្រង ទោះតាមផ្លូវច្បាប់ រឺតាមការអនុវត្តជាក់ស្ដែងក្ដី ។ ផ្ទុយទៅវិញ បណ្ដាក្រុមហ៊ុនក្នុងប្រព័ន្ធរៀបរយអាចសំគាល់បានតាមការជួលប្រើបុគ្គលិកដោយមានកិច្ចសន្យា ដែលមានចែងច្បាស់ពីសិទ្ធិ ភារៈកិច្ច ខ្សែរយៈគ្រប់គ្រង និងលក្ខខណ្ឌនៃការជ្រើសជួល និងបញ្ឈប់បុគ្គលិក ។ ពលករនានាស្ថិតក្រោមកិច្ចការពារពីច្បាប់ការងារដែលត្រូវបានដាក់អនុវត្ត និងលើកកំពស់ដោយអង្គភាពរបស់ខ្លួនផ្ទាល់។ នៅក្រោមលក្ខខណ្ឌទាំងនេះ បុគ្គលនីមួយៗលក់កំលាំងពលកម្មរបស់ខ្លួនទៅឱ្យក្រុមហ៊ុនក្នុងរយៈពេលមួយមានកំណត់ច្បាស់ ហើយទទួលបានមកវិញនូវប្រាក់បំណាច់យ៉ាងទៀងទាត់ (Portes 1983) ។ តាមការប៉ាន់ស្មានរបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ២០០៣ ពលករក្នុងវិស័យក្រៅប្រព័ន្ធតំណាងឱ្យ ៨៥% នៃកំលាំងពលកម្មសរុបនៅកម្ពុជា និងរួមចំណែកបាន ៦២% នៃផលិតផលក្នុងស្រុកសរុប ដូច្នេះបានរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា (EIC 2006) ។

បច្ចុប្បន្ន មានក្រុមអ្នកស្រាវជ្រាវជាច្រើនដែលមានការយល់ឃើញខុសៗគ្នា អំពីទំនាក់ទំនងរវាងសេដ្ឋកិច្ចរៀបរយ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយគេអាចបែងចែកជា អ្នកទ្វិកនិយម អ្នកច្បាប់និយម និង អ្នករចនាសម្ព័ន្ធនិយម ។ អ្នកទ្វិកនិយម យល់ថាសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចបន្ទាប់បន្សំដាច់ដោយឡែក និងមិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសេដ្ឋកិច្ចរៀបរយទេ ហើយវាផ្ដល់ប្រាក់ចំណូល ឬប្រព័ន្ធសុវត្ថិភាពសំរាប់ប្រជាជនក្រីក្រ ។ អ្នកច្បាប់និយមអះអាងថា របៀបរបបធ្វើការងារក្រៅប្រព័ន្ធ គឺជាការឆ្លើយតបសមហេតុផលមួយនៃសហគ្រិនខ្នាតតូច ចំពោះបទបញ្ញត្តិច្រើនលើសលប់ក្នុងប្រព័ន្ធការិយាធិបតេយ្យរបស់រដ្ឋាភិបាល ។ ចំណែកឯអ្នករចនាសម្ព័ន្ធនិយមវិញបានអះអាងថា សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺពួកមូលធននិយមបានដាក់វាឱ្យស្ថិតនៅក្រោមសេដ្ឋកិច្ចរៀបរយ ពីព្រោះពួកគេចង់កេងយកចំណេញពីអ្នកផលិត និងអ្នកជំនួញខ្នាតតូច ដើម្បីកាត់បន្ថយតម្លៃដើម (Chen et al. 2002) ។

កន្លងមក រដ្ឋាភិបាលបានអនុម័តប្រើវិធីសាស្ត្រទ្វិកយូរឆ្នាំពេកហើយ បានធ្វើសកម្មភាពដោយផ្អែកលើការសន្និដ្ឋានថា សេដ្ឋកិច្ចក្រៅប្រព័ន្ធនឹងរួមតូចជាបណ្ដើរៗដោយខ្លួនឯង នៅពេលសេដ្ឋកិច្ចរៀបរយរីកលូតលាស់ឡើង ។ ជំហរនេះ បាននាំឱ្យមានលក្ខណៈលំអៀងជាច្រើននៅក្នុងគោលនយោបាយដែលបានគាំទ្រដល់សេដ្ឋកិច្ចរៀបរយ និងធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ រដ្ឋាភិបាលត្រូវតែកសាងគោលនយោបាយមួយ ដែលទទួលស្គាល់សារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដាក់កំហិត និងដាក់បទបញ្ញត្តិគ្រប់គ្រងវាតាមការចាំបាច់ ប៉ុន្តែសំខាន់បំផុត គឺដើម្បីបង្កើនផលិតភាព និងកែលំអលក្ខខណ្ឌការងាររបស់ពួកអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (Becker ២០០៤) ។ ដូចបានលើកឡើងនៅក្នុងសម័យប្រជុំលើកទី៨៩ នៃសន្និសីទពលកម្មអន្តរជាតិ នៅខែមិថុនា ២០០១ "បញ្ហាប្រឈមធំបំផុតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺ តើត្រូវបញ្ចូលសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងសេដ្ឋកិច្ចរៀបរយដោយរបៀបណា? នេះជាបញ្ហាផ្នែកសមធម៌ និងសាមគ្គីភាពក្នុងសង្គម។ គោលនយោបាយត្រូវតែជំរុញឱ្យមានការផ្លាស់ប្ដូរចេញពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយសង្គមទាំងមូលត្រូវផ្ដល់ថវិកា សំរាប់ជួយទ្រទ្រង់ដល់ក្រុមងាយរងគ្រោះនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ។

អន្តរកាលពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទៅសេដ្ឋកិច្ចរៀបរយ តាមធម្មតាធ្វើឡើងជាបណ្ដើរៗ ហើយបញ្ហាប្រឈម គឺត្រូវបង្កើតនីតិវិធីផ្សេងៗដែលអាចជួយទ្រទ្រង់ដល់សហគ្រាសនានា ឱ្យមានលក្ខណៈសម្បត្តិកាន់តែផ្លូវការឡើង (តារាង១) ។ សហគ្រាស្រ្តខ្នាតតូច តែងធ្វើការគណនាសេដ្ឋកិច្ចតាមបែបការវិភាគចំណាយ និងផលចំនេញដោយកំណត់នូវកម្រិតអប្បរមាមួយនៃការចូលរួមអនុវត្តរបៀបរបបផ្លូវការ ដែលក្នុងនោះបន្ទុកចំណាយវានៅទាបជាងផលចំណេញ ។ ដូច្នេះ សហគ្រាសខ្លះនឹងជ្រើសរើសចូលរួមអនុវត្តតែរបៀបរបបមួយចំនួនប៉ុណ្ណោះ នៅក្នុងពេលជាក់លាក់ណាមួយ ពីព្រោះបន្ទុកចំណាយ និងផលចំនេញក្នុងការចូលរួមអនុវត្តរបៀបរបបផ្លូវការ វាប្រែប្រួលខុសគ្នាទៅតាមសហគ្រាសដែលមានទំហំ និងអាយុកាលខុសគ្នា (Becker ២០០៤) ។ សកម្មភាពអាជីវកម្មនៅផ្សារ មានលក្ខណៈក្រៅផ្លូវការជាខ្លាំង

---

* ដោយសមាជិកក្រុម ក្នុងគំរោង ការវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) នៃគណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា គឺមាន លោក ហាក់ សុចាន់នី លោក អឿ អ៊ីល លោក ខួន ចាន់ដូរ៉េ និង John Mc Andrew ។

ដូច្នេះត្រូវមានការយកចិត្តទុកដាក់រួមគ្នាពីរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីបង្កើនផលិតភាព និងជួយពួកគេឱ្យទទួលបាននូវសិទ្ធិពលករសាកល ។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់មូលដ្ឋានបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០០៧ ជាមួយអាជីវករអ្នកលក់ដូរទំនិញនៅជុំវិញផ្សារចំនួន ៣ គឺផ្សារបឹងកុក ផ្សារក្រមួន និងផ្សារសាលាចិន នៅទីរួមខេត្តកំពង់ចាម ។ ការស្រាវជ្រាវនេះបានសំភាសជាមួយអ្នកលក់បន្លែ ផ្លែឈើ ឬត្រី ទាំងអស់ ២១៥នាក់ ដោយបានខិតខំជ្រើសយកឱ្យបានចំនួនប៉ុនគ្នានូវអ្នកលក់ទំនិញទាំងបីមុខនេះ ។ តាមការប៉ាន់ស្មានច្បោល១ គេឃើញថា នៅម៉ោងមមាញឹកបំផុតក្នុងពេលព្រឹក មានអាជីវករប្រមាណ ៧៥០នាក់ មកលក់ទំនិញនៅផ្សារធំ១ទាំងបីនេះ ។ ការសំភាសត្រូវប្រើពេលខ្លី ពីព្រោះធ្វើឡើងក្នុងពេលលក់ដូរនៅកន្លែងលក់ផ្ទាល់ ។ បញ្ហាត្រូវសួរផ្តោតលើៈ ១) ព័តិមានសង្ខេបលើអាជីវករ និងតួនាទីនៃអ្នករកប្រាក់សំរាប់គ្រួសារ ២) ប្រតិបត្តិការអាជីវកម្មរួមមានដើមទុនវិនិយោគដំបូង លទ្ធភាពទទួលបានប្រាក់កម្ចី និងការផ្គត់ផ្គង់ទំនិញ ប្រាក់ចំណូល និងប្រាក់ចំណេញប្រចាំថ្ងៃ និង ៣) សិទ្ធិលើកន្លែងលក់ដូរ ។ បន្ថែមលើបញ្ជីសំនួរអង្កេត គឺបានធ្វើសំភាសលំអិតជាមួយអ្នកផ្តល់ព័តិមានគន្លឹះដែលជាអាជីវករបានជ្រើសរើសមួយចំនួន ហើយភាគច្រើនធ្វើនៅលំនៅដ្ឋានរបស់ពួកគេ ក្រោយផុតម៉ោងលក់ដូរមមាញឹកបំផុតនៅផ្សារ ។ ការសំភាសលំអិតទាំងនេះ ដែលមួយចំនួនមានចុះក្នុងរបាយការណ៍ពេញលេញ ផ្តល់ព័តិមានស៊ីជំរៅពីបញ្ហាប្រឈមរបស់អាជីវករ ។ ការសំភាសអ្នកផ្តល់ព័តិមានគន្លឹះ ក៏បានធ្វើឡើងជាមួយមន្ត្រីគណៈកម្មាធិការផ្សារ ដើម្បីទទួលបានព័តិមានពីទំនាក់ទំនងរវាងអ្នកលក់ដូរ និងអ្នកលក់ដុំ និងរវាងអ្នកលក់រាយតាមតូបក្នុងផ្សារ និងអ្នកប្រមូលភាស៊ីផ្សារ ។

## ព័ត៌មានលើអាជីវករនៅផ្សារ

ចំណុចគួរកត់សំគាល់មួយគឺ ៩៧% នៃអាជីវករបានធ្វើសំភាសន៍សុទ្ធជានារី ។ អាជីវករអ្នកឆ្លើយសំភាសន៍មាន អាយុជាមធ្យម ៤០,៦ឆ្នាំ ក្នុងនេះ ៥៧% មានអាយុពី ៣០ ដល់ ៤៩ឆ្នាំ, ៣៤% បានបញ្ចប់ការសិក្សាកំរិតបឋមសិក្សា ឬការសិក្សាកំរិតខ្ពស់ និង ១៨% មិនដែលបានចូលរៀនទេ ។ កំរិតអប់រំទាបជាទូទៅ និងកង្វះជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ អាចជាមូលហេតុមួយដែល ៨០% នៃអាជីវករទាំងនេះមិនធ្លាប់រកប្រាក់បានពីមុខរបរអ្វីផ្សេងទេ ។ កត្តាអាយុច្រើន និងកំរិតអប់រំទាប ក៏ធ្វើឱ្យពួកគេពិបាករកបានការងារនៅតាមរោងចក្រកាត់ដេរក្នុងក្រុងភ្នំពេញដែរ ។ ក្នុងចំណោមអ្នកឆ្លើយសំភាសន៍ មាន ៩៣% បានមករស់នៅក្នុងទីរួមខេត្តកំពង់ចាមតាំងពីមុនឆ្នាំ២០០០ ប៉ុន្តែមាន ៥២% បានមកលក់ដូរនៅផ្សារចាប់ពីឆ្នាំ២០០០ ប៉ុណ្ណោះ ដើម្បីឆក់យកឱកាសល្អនៃការរីដុះដាលសេដ្ឋកិច្ច[២] ។

អាជីវករផ្សារ ៨៧% សុទ្ធតែជាអ្នកមានគ្រួសារហើយ ១៧% ជាស្ត្រីមេម៉ាយនិងបុរសពោះម៉ាយ៤%ទៀតរស់នៅបែកលំនៅដ្ឋានរីលែងលះគ្នា ។ ចំនួនមធ្យមនៃកូននៅរស់របស់អាជីវករ ដែលរៀបអាពាហ៍ពិពាហ៍ហើយរឺបានរៀបការពីមុន គឺ ៣,៣នាក់ ហើយចំនួនកូនដែលនៅផ្ទះជាមធ្យម

*ក្រាហ្វិក ១: ការវិវត្តពីវិស័យក្រៅប្រព័ន្ធ ទៅវិស័យផ្លូវការ*

| | វិស័យក្រៅប្រព័ន្ធ | | វិស័យផ្លូវការក្នុងប្រព័ន្ធ |
|---|---|---|---|
| | *របររកបានតែមួយរស់* | *របរមិនផ្លូវការ* | *របរមិនផ្លូវការ* / *របរផ្លូវការ* |
| *កំរិតនៃភាពក្រៅប្រព័ន្ធ* | ១០០% | ចំនួនខ្ពស់នៃការលក់មិនបានប្រកាស និងពលករមិនបានចុះបញ្ជីការងារ | ចំនួនខ្លះនៃការលក់មិនបានប្រកាស និងពលករមិនបានចុះបញ្ជីការងារ |
| *ប្រភេទសកម្មភាព* | អ្នកលក់ដូរម្នាក់ឯងតាមផ្លូវ របរតាមគ្រួសារ កសិកររកតែមួយរស់ | សិប្បកម្មផលិតខ្នាតតូច អ្នកផ្តល់សេវា អ្នកចែកចាយ អ្នកម៉ៅការ | សិប្បកម្មផលិតខ្នាតតូច និងមធ្យម អ្នកផ្តល់សេវា សហគ្រាសសូហ្វៀរ |
| *បច្ចេកវិទ្យា* | អតិពលកម្ម | អតិពលកម្មភាគច្រើន | ចំណេះដឹង និងប្រើមូលធនច្រើន |
| *ពណ៌នាសង្ខេបពីម្ចាស់អាជីវកម្ម* | ក្រីក្រ ការអប់រំតិច កំរិតជំនាញទាប | ក្រីក្រ និងមិនក្រីក្រ ការអប់រំល្អ កំរិតជំនាញខ្ពស់ | មិនក្រីក្រ ការអប់រំខ្ពស់ កំរិតជំនាញខ្ពស់និងល្អិតល្អន់ |
| *ផ្សារ* | របាំងច្រកចូលទាប កំលាំងប្រកួតប្រជែងខ្ពស់ ផលិតផលដូចគ្នាខ្លាំង | របាំងច្រកចូលទាប កំលាំងប្រកួតប្រជែងខ្ពស់ ផលិតផលមានខុសគ្នាខ្លះ | របាំងច្រកចូលខ្ពស់ មានទីផ្សារជាប់លាប់ មានទីផ្សារដោយឡែកសំរាប់ផលិតផល |
| *តំរូវការហិរញ្ញវត្ថុ* | ទុនដំណើការ | ទុនដំណើរការ ទុនវិនិយោគមួយចំនួន ឥណទានអ្នកផ្គត់ផ្គង់ | ទុនវិនិយោគ និងទុនដំណើការ ប័ណ្ណឥណទាន ឥណទានអ្នកផ្គត់ផ្គង់ |
| *តំរូវការផ្សេង១* | ការធានារ៉ាប់រងផ្ទាល់ខ្លួន ការគាំពារពីសង្គម | ការធានារ៉ាប់រងផ្ទាល់ខ្លួន អាចមានការធានារ៉ាប់រងអាជីវកម្ម | ការធានារ៉ាប់រងផ្ទាល់ខ្លួន និងអាជីវកម្ម សេវាអភិវឌ្ឍន៍អាជីវកម្ម |
| | *មានសន្ទុះខ្សោយបំផុត ក្រៅប្រព័ន្ធទាំងស្រុង* → | | *មានសន្ទុះខ្លាំង ក្រៅប្រព័ន្ធមួយចំណែក* |

*ប្រភពៈ The Informal Round Table, Sofia, 18–20 April 2002, Simeon Djankov, Ira Lieberman, Joyita Mukherjee, Tatiana Nenova, “Going Informal: Benefits and Costs”, cited in Becker 2004*

តារាង ១: តួនាទីអាជីវករផ្សារជាអ្នករកប្រាក់ចំណូលក្នុងគ្រួសារនៅទីរួមខេត្តកំពង់ចាម ខែកញ្ញា ២០០៧

| | អាជីវករលក់បន្លែ | | អាជីវករលក់ផ្លែឈើ | | អាជីវករលក់ត្រី | | អាជីវករទាំងអស់ | |
|---|---|---|---|---|---|---|---|---|
| | # | % | # | % | # | % | # | % |
| អ្នករកចំណូលគ្រួសារតែឯង | 28 | 36 | 25 | 36 | 25 | 37 | 78 | 36 |
| អ្នករកចំណូលគ្រួសារចំបង (លើស ៥០% នៃចំណូលគ្រួសារ) | 20 | 26 | 19 | 27 | 29 | 43 | 68 | 32 |
| អ្នករកចំណូលគ្រួសារតែឯង រឺ ចំបង | 48 | 62 | 44 | 63 | 54 | 79 | 146 | 68 |
| | N=77 | | N=70 | | N=68 | | N=215 | |

គឺ ២,៤នាក់ និងចំនួនកូនអាយុ៥ឆ្នាំ និងក្រោម៥ឆ្នាំនៅផ្ទះជាមធ្យមគឺ ០,៣នាក់ ។ ជាទូទៅអាជីវករដែលធ្វើអង្កេត ត្រូវទទួលខុសត្រូវចំពោះកូន ប៉ុន្តែពួកគេមិនមានបន្ទុកខ្លាំងក្នុងការមើលថែកូន ដែលគ្រប់អាយុចូលថ្នាក់មត្តេយ្យនោះទេ ។ ផ្សារនៅក្នុងទីរួមខេត្តកំពង់ចាម ផ្តល់ឱកាសច្រើនដល់អាជីវករដែលអាចរកលុយនៅក្បែរផ្ទះផង និងអាចបំពេញកាតព្វកិច្ចប្រពៃណីក្នុងការមើលថែកូនផង ។

## ការចូលរួមចំណែកក្នុងលក្ខណៈជាអ្នករកចំណូលសំរាប់គ្រួសារ

ក្នុងគ្រួសារអាជីវករផ្សារ សមាជិកដែលរស់នៅ និងហូបចុកជាមួយគ្នាមានចំនួនជាមធ្យម ៥,៣នាក់ ប៉ុន្តែសមាជិកមធ្យមដែលចូលរួមចំណែកដោះស្រាយជីវភាពគ្រួសារមានតែ ១,៩នាក់ ប៉ុណ្ណោះ ។ កត្តានេះបញ្ជាក់ពីសារៈសំខាន់នៃអាជីវករផ្សារ ពីព្រោះរបរនេះធ្វើឱ្យពួកគេស្ថិតក្នុងចំណោមសមាជិកអ្នកទ្រទ្រង់ជីវភាពគ្រួសារ ។ ទិន្នន័យបន្ថែមបង្ហាញថា ៦៨% នៃអាជីវករជ្រើសយកជាគំរូតាង គឺជាអ្នករកចំណូលតែឯង ឬជាអ្នករកចំណូលចំបងនៅក្នុងគ្រួសារ (តារាង ១) ។ ដោយសារកំលាំងនៃតួនាទីជាអ្នករកចំណូលផ្គត់ផ្គង់គ្រួសារ និងតួនាទីជាប្រពៃណីរបស់ស្ត្រីក្នុងសង្គមកម្ពុជា អាជីវករផ្សារមានសិទ្ធិអំណាចធំណាស់ ក្នុងការត្រួតត្រារឿងប្រាក់កាស និងការចាយវាយនៅក្នុងគ្រួសារ ។ គិតជារួម អាជីវករគំរូតាងប្រហែល ៨០% រក្សាទុកប្រាក់កាសនៅក្នុងគ្រួសារ ។

តួលេខទាំងនេះ បានបដិសេធសុភាសិតខ្មែរ "ស្ត្រីបង្វិលចង្ក្រានមិនជុំ" ដែលមានន័យថា ស្ត្រីមិនអាចចេញផុតពីចង្ក្រានបាយ ដើម្បីទៅរកចំណូលទេ ។ ជាក់ស្តែងអាជីវករផ្សារដែលជ្រើសយកជាគំរូតាងសំរាប់អង្កេតនេះ ភាគច្រើនជាអ្នករកចំណូលចំបងមកចិញ្ចឹមក្រុមគ្រួសារ និងមិនមែនជាមេផ្ទះពឹងផ្អែកតែលើចំណូលដែលប្តីរកបាន ដូចពាក្យក្នុងសុភាសិតនេះទេ ។

*ក្រាហ្វិក ២: ប្រាក់ចំណេញប្រចាំថ្ងៃមធ្យមរបស់អាជីវករផ្សារ គិតជាភាគរយ នៃប្រាក់លក់បានសរុបប្រចាំថ្ងៃជាមធ្យម ទីរួមខេត្តកំពង់ចាម ខែកញ្ញា ២០០៧*



តារាង ២: ប្រាក់ចំនេញមធ្យមប្រចាំថ្ងៃ (ជារៀល) របស់អាជីវករផ្សារក្នុងទីរួមខេត្តកំពង់ចាម ខែកញ្ញា ២០០៧

| | អាជីវករលក់បន្លែ | | អាជីវករលក់ផ្លែឈើ | | អាជីវករលក់ត្រី | | អាជីវករទាំងអស់ | |
|---|---|---|---|---|---|---|---|---|
| | # | % | # | % | # | % | # | % |
| ១000-៥000 រៀល | 31 | 42 | 21 | 30 | 14 | 21 | 66 | 31 |
| ៥00១-១0.000 រៀល | 28 | 37 | 26 | 38 | 36 | 53 | 90 | 42 |
| ១0.00១-១៥.000 រៀល | 8 | 11 | 11 | 16 | 9 | 13 | 28 | 13 |
| លើសពី ១៥.000 រៀល | 9 | 12 | 11 | 16 | 9 | 13 | 29 | 14 |
| | N=76 | | N=69 | | N=68 | | N=213 | |

## ការទិញអីវ៉ាន់មកលក់

ដើមទុនវិនិយោគដំបូងជាមធ្យមរបស់អាជីវករក្នុងអង្កេតគឺ ១៥៤.១៨២រៀល (៣៨,៥៥ដុល្លារអាមេរិក) ។ ទឹកប្រាក់មិនសូវច្រើននៃវិនិយោគដំបូងសំរាប់ចាប់ផ្ដើមដំណើការលក់ដូរ ធ្វើឱ្យអាជីវករប្រហែល ៥0% អាចដោះស្រាយដើមទុនសំរាប់អាជីវកម្មខ្នាតតូចនេះបានដោយប្រើប្រាក់កាសរបស់ខ្លួនផ្ទាល់ ។ អាជីវករប្រហែល ២0% ទៀតរកបានដើមទុនវិនិយោគដំបូងមួយភាគធំពីអ្នកលក់ដុំ រឺពួកពាណិជ្ជករ ។ អាជីវករផ្សារប្រហែលពីរភាគបី ទិញអីវ៉ាន់ពីអ្នកលក់ដុំ ឬឈ្មួញកណ្ដាល ។ អាជីវករមួយចំនួនទិញអីវ៉ាន់ ដោយទូទាត់ជាសាច់ប្រាក់ដល់ដៃទាំងអស់ និងមួយចំនួនទៀតបង់ជាសាច់ប្រាក់ខ្លះ និងសុំជំពាក់ខ្លះ ហើយអ្នកខ្លះទៀតទិញជំពាក់គេទាំងអស់។ គួរកត់សំគាល់ថា អាជីវករភាគច្រើន ដែលទិញអីវ៉ាន់ជំពាក់គេខ្លះ ឬជំពាក់គេទាំងអស់ ត្រូវសងប្រាក់ជំពាក់នោះវិញនៅចុងថ្ងៃដដែលនោះ ។ សម្រាប់អាជីវករប្រហែល ២៥% អ្នកលក់ដុំគេដឹកទំនិញទៅឱ្យដល់កន្លែងលក់ ។

ចំណងទាក់ទងរវាងអ្នកលក់ដុំ និងអាជីវករផ្សារ គឺជាខ្សែចង្វាក់ទីផ្សារដែលសំខាន់ប៉ុនគ្នានឹងខ្សែរយៈរវាងអ្នកលក់ដុំ និងអ្នកលក់រាយតាមតូបក្នុងផ្សារដែរ ។ អ្នកលក់ដុំផ្ដល់ដើមទុនវិនិយោគ ប្រាក់ជំពាក់ប្រចាំថ្ងៃ និងការជួយដឹកជញ្ជូនទៅដល់អាជីវករផ្សារ ហើយអាជីវករផ្សារដើរតួជាឈ្មួញកណ្ដាលដែលជួយឱ្យអ្នកលក់ដុំអាចលក់ដូរ និងចែកចាយទំនិញបានធំទូលាយទៅដល់អតិថិជនជាច្រើន ក្រៅពីអ្នកមកទិញទំនិញពីអ្នកលក់រាយតាមតូបក្នុងផ្សារទៅទៀត។

## ចំណូលប្រចាំថ្ងៃ

ប្រាក់ចំណេញប្រចាំថ្ងៃជាមធ្យមរបស់អាជីវករផ្សារ គឺ ១0.៣៣៣រៀល (២,៥៨ដុល្លារអាមេរិក) ដែលស្មើនឹង ៧,៦% នៃប្រាក់លក់បានសរុបប្រចាំថ្ងៃមធ្យម ១៣៥.៥២៧រៀល (ក្រាហ្វិក ២) ។ ដូច្នេះអាជីវករធ្វើការលក់ដូរដោយប្រើសាច់ប្រាក់យ៉ាងច្រើន និងមានប្រាក់ចំណូលដុលច្រើនដែរ ប៉ុន្ដែមានកំរិតប្រាក់ចំនេញមធ្យមទាប ។ កំរិតប្រាក់ចំណេញនេះ ក៏ខុសគ្នាខ្លាំងដែរក្នុងចំណោមអាជីវករ ។ អាជីវករ ៣១% ទទួលបានប្រាក់ចំនេញប្រចាំថ្ងៃមធ្យម ៥000រៀល ឬតិចជាង ហើយ ១៤% ទៀត ទទួលបានច្រើនជាង ១៥.000រៀល (តារាង ២) ។ តួលេខនេះបង្ហាញពីគំលាតរវាងអាជីវករនានាក្នុងការទទួលបានឥណទាន លទ្ធភាពគ្រប់គ្រងអាជីវកម្ម ទំហំប្រតិបត្តិការលក់ដូរ និងសមត្ថភាពរីកលូតលាស់ ។

ដោយសារចំនួនភាគរយខ្ពស់របស់អាជីវករដែលមានប្រាក់ចំណូលប្រចាំថ្ងៃតិចជាង ៥.000រៀល ហើយមានចំនួនសមាជិកគ្រួសារជាមធ្យមដល់ ៥,៣នាក់ និងមានតួនាទីជាអ្នករកប្រាក់ចំណូលចំបងសំរាប់គ្រួសារ ដូច្នេះអាជីវករជាច្រើននៅក្នុងអង្កេតនេះ ហាក់ដូចជាលក់ដូរបានតែមួយរស់ប៉ុណ្ណោះ[៣] ។ អាជីវករតិចនាក់ណាស់ ដែលមានស្ថានភាពហិរញ្ញវត្ថុមាំទាំ និងមានជីវភាពខ្ពស់ជាងកំរិតមួយរស់ ។ ប៉ុន្ដែទោះបីការលក់ដូរនៅផ្សារបានត្រឹមមួយរស់ រឺក៏បានលើកស្ទួយជីវភាពក្ដី ក៏វាមានតំលៃជាខ្លាំងចំពោះជីវិតរស់នៅរបស់ស្ដ្រីម្នាក់ៗ ។ ជាក់ស្ដែង អ្នកលក់ដូរប្រហែល ៧៥% និយាយថា ពួកគេពេញចិត្ដនឹងការងាររបស់ខ្លួន ហើយមានអ្នកលក់ដូរជាង ៦៥% អះអាងថា មុខរបរនេះធ្វើអោយពួកគេ អាចផ្គត់ផ្គង់គ្រួសារ និងចិញ្ចឹមកូនបាន ។

ចំនួនម៉ោងធ្វើការប្រចាំថ្ងៃជាមធ្យមរបស់អាជីវករ គឺ ៧,៨ម៉ោង ។ អាជីវករជាង ៦0% ដំណើរការរបរលក់ដូររបស់ខ្លួនដោយខ្លួនឯងតែម្ដង ឯអ្នកខ្លះទៀតមានសាច់ញាតិមកជួយលក់ក្នុងពេលមមាញឹកខ្លាំង ។ មានអាជីវករតិចនាក់ណាស់ដែលបានទទួលការណែនាំ ឬការបណ្ដុះបណ្ដាលពីរបៀបប្រកបរបរលក់ដូរ និងមានរឹតតែតិចនាក់ទៀតដែលធ្វើកំនត់ត្រាពីចំណូល-ចំណាយប្រចាំថ្ងៃ ។ អាជីវករជាង ៥0% បានប្រាប់ថា ពួកគេមានគំរោងពង្រីកការលក់ដូរ និងបង្កើនមុខទំនិញ ប៉ុន្ដែកំពុងជួបឧបសគ្គចំបងមួយ គឺកង្វះលទ្ធភាពទទួលបានដើមទុនបន្ថែម[៤] ។

## កន្លែងលក់ដូរ និងប្រាក់កំរៃបង់នៅផ្សារ

អាជីវករមានសិទ្ធិប្រើប្រាស់កន្លែងលក់ដូររបស់ខ្លួន ប៉ុន្ដែសិទ្ធិនេះមិនមែនដាច់ណាត់ទេ ។ គួរកត់សំគាល់ថា អាជីវករក្នុងអង្កេតប្រហែល ៤0% ត្រូវបានបណ្ដេញចេញពីកន្លែងលក់ដូរចាស់របស់ខ្លួន ។ ចំពោះសំនួរពីលទ្ធភាពត្រូវគេបណ្ដេញចេញពីកន្លែងលក់ដូរបច្ចុប្បន្ននេះ អាជីវករប្រហែល ២0% ឆ្លើយថាអាចត្រូវគេដេញ និង ៤0% ទៀតមិនច្បាស់ក្នុងចិត្ត ។ អាជីវករប្រហែល ១៥% ដែលឆ្លើយសំភាសន៍ ធ្លាប់ត្រូវអាជ្ញាធរបណ្ដេញចេញពីកន្លែងលក់ដូរបច្ចុប្បន្ននេះរួចហើយ ។ ម្យ៉ាងទៀតអាជីវករ ១៥% ធ្លាប់ត្រូវនគរបាល រឺសន្ដិសុខផ្សារ រឹបអូសយកទំនិញពីកន្លែងលក់ដូរបច្ចុប្បន្នរបស់ពួកគេ ។ ស្ថានភាពខាងផ្លូវច្បាប់មិនច្បាស់លាស់របស់អាជីវករ ធ្វើឱ្យពួកគេងាយរងគ្រោះដោយការបណ្ដេញ និងការរំខានរុកគួនពីពួកអាជ្ញាធរ ។ អាជីវករ គួរតែទទួលបានលក្ខណៈច្បាប់ច្បាស់លាស់ ដើម្បីមានសិទ្ធិប្រកប

របរលក់ដូរ និងមានសិទ្ធិមានកន្លែងលក់ដូរ (សូមមើល Kusakabe 2006 b)[៥] ។

អ្នកឆ្លើយសំភាសន៍ស្ទើរតែគ្រប់គ្នាបានបង់ភាសុី (ពន្ធអាជីវកម្មប្រចាំថ្ងៃ) លើទំនិញដែលដាក់លក់ ។ អាជីវករជិតពាក់កណ្តាលត្រូវបង់ថ្លៃកន្លែងលក់ដូរផងដែរ ។ អាជីវករភាគច្រើនបានបង់ថ្លៃឈ្នួលឆ័ត្រ និងថ្លៃប្រើបង្គន់ និងសេវាអនាម័យផ្សេងៗ ប៉ុន្តែនៅតែត្រូវជួបបញ្ហាខ្លិនស្អុយសំរាមមិនទាន់ ប្រមូលចេញ ក្លិនភក់ជ្រាំនៅជុំវិញកន្លែងលក់កណ្តុរ និងសត្វល្អិតផ្សេងៗ និងកង្វះបង្គន់ និងទឹកស្អាត ។ អាជីវករផ្សារ ត្រូវបង់ជាមធ្យម ២.១៣៥រៀល/ថ្ងៃ ($0,៥៣) សំរាប់ថ្លៃផ្សេងៗនៅផ្សារ ។ អ្នកជាប់ពន្ធភាសុី ត្រូវបង់ជាមធ្យម ១.0២១រៀលក្នុងមួយថ្ងៃ ($0,២៦) ។ ជាទូទៅ អាជីវករមិនត្អូញត្អែរលើការបង់ប្រាក់តាមស្តង់ដារត្រឹមត្រូវនោះទេ ប៉ុន្តែលើការបង់ប្រាក់ច្រើនហួសហេតុ ដែលអ្នកប្រមូលពន្ធបានទារបន្ថែមនៅពេលខ្លះ ។ ថ្វីបើក្នុងចំណោមអាជីវករឆ្លើយសម្ភាសន៍ពុំមាននរណាម្នាក់ជាសមាជិកក្រុម រឺសមាគមអាជីវករណាមួយក្តី ក៏ពួកអាជីវករនៅផ្សារបឹងកុក ដោយមានការគាំទ្រពីក្រុមអង្គការសិទ្ធិមនុស្សធ្លាប់ធ្វើសកម្មភាពតវ៉ាបានជោគជ័យ ប្រឆាំងនឹងការទារពន្ធអាជីវកម្មលើសចំនួន ។

## សន្និដ្ឋាន

ជាទូទៅ ការសិក្សានេះ ផ្តល់លទ្ធផលស្របគ្នាជាមួយនឹងឯកសារដែលមានស្រាប់ស្តីពីអាជីវករផ្សារនៅរាជធានីភ្នំពេញ ។ ពិតមែនតែអាជីវករផ្សារធ្វើការងារច្រើនម៉ោង និងរួមចំណែកយ៉ាងសំខាន់ក្នុងការរកប្រាក់ចំណូលសំរាប់គ្រួសារ ប៉ុន្តែកង្វះការអប់រំមុខជំនាញ កង្វះលទ្ធភាពទទួលបានដើមទុន និងលទ្ធភាពទទួលបានការងារ វាកាត់បន្ថយផលិតភាព និងប្រាក់ចំណេញរបស់ពួកគេ ធ្វើអោយពួកគេភាគច្រើនមិនអាចចេញផុតពីស្ថានភាពរកបានតែមួយរស់ ។ លើសពីនេះទៅទៀត លក្ខណៈផ្លូវច្បាប់មិនជាក់លាក់របស់ពួកគេ និងការស្ថិតនៅខាងក្រៅច្បាប់ការងារ ធ្វើអោយពួកគេងាយរងគ្រោះដោយការរំលោភសិទ្ធិ និងគ្មានអ្វីការពារខ្លួនចំពោះព្រឹត្តិការណ៍ឥតព្រាងទុក ។ សំរាប់អាជីវករផ្សារនានា កង្វះការងារ សិទ្ធិការគាំពារខាងសង្គមកិច្ច និងអ្នកតំណាង នៅមានកំរិតខ្ពស់ និងត្រូវដោះស្រាយជាបន្ទាន់ ។

ការសិក្សាពីស្ថានភាពអាជីវករផ្សារនៅទីរួមខេត្តកំពង់ចាម ដែលស្ថិតក្នុងបរិបទសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ បានបង្ហាញពីភាពលំអៀងរបស់រដ្ឋាភិបាលកម្ពុជាទៅខាងវិស័យសេដ្ឋកិច្ចរៀបរយ ។ ស្របតាមវិធីសាស្ត្រទ្វិក រដ្ឋាភិបាលបានសន្និដ្ឋានថា សេដ្ឋកិច្ចក្រៅប្រព័ន្ធនឹងរួមតូចជាបណ្តើរៗ ព្រមគ្នានឹងការរីកលូតលាស់វិស័យសេដ្ឋកិច្ចរៀបរយ ប៉ុន្តែជាក់ស្តែងក្នុងពេលកន្លងមក រឿងរ៉ាវមិនបានកើតឡើងដូច្នេះទេ ។ ការសិក្សានេះបង្ហាញថា រដ្ឋាភិបាលត្រូវកសាងគោលនយោបាយ និងផ្តួចផ្តើមដំណើការ ដើម្បីធ្វើឱ្យសហគ្រាសក្រៅប្រព័ន្ធទទួលបានលក្ខណៈរៀបរយឡើង ។ ចំពោះសកម្មភាពលក់ដូរនៅផ្សារដែលមានលក្ខណៈក្រៅប្រព័ន្ធជាខ្លាំង គឺត្រូវមានសកម្មភាពស៊ីចង្វាក់គ្នារបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនផលិតភាព និងការអនុវត្តតាមគោលការណ៍សិទ្ធិពលករសាកល ។

## អនុសាសន៍គោលនយោបាយ

បន្ទាប់ពីការងារស្រាវជ្រាវនេះបានបញ្ចប់ និងស្របតាមការសិក្សានាពេលថ្មីៗស្តីពីអាជីវករផ្សារ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ដែលផ្តល់មូលនិធិដោយអង្គការពលកម្មអន្តរជាតិ (Kusakabe 2006a, 2006b; EIC 2006) ការសិក្សានេះបានចងក្រងជាអនុសាសន៍គោលនយោបាយជាច្រើន ជូនដល់រដ្ឋាភិបាល និងសង្គមស៊ីវិលដូចតទៅ:

១. លុបបំបាត់ច្បាប់ទាំងឡាយណាដែលកំណត់ថា ការលក់ដូរនៅផ្សារជាសកម្មភាពខុសច្បាប់
២. ពង្រីកដែនអនុវត្តច្បាប់ស្តីពីប្រព័ន្ធសុវត្ថិភាពសង្គម និងច្បាប់ការងារនៅកម្ពុជា ដើម្បីគ្របដណ្តប់ផងដែរ ទៅលើអាជីវករផ្សារ និងពលករក្រៅប្រព័ន្ធ
៣. ដាក់បញ្ចូលអាជីវករផ្សារ និងពលករក្រៅប្រព័ន្ធនានា ទៅក្នុងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ចនៅផ្សារ
៤. លើកកំពស់តួនាទីអ្នកតំណាងរបស់អាជីវករផ្សារ និងពលករក្រៅប្រព័ន្ធនៅក្នុងសមាគមពលករនានា
៥. បង្កើនជំនាញ ចំណេះដឹង និងលទ្ធភាពទទួលបានដើមទុនរបស់អាជីវករផ្សារ ដើម្បីបង្កើនផលិតភាព និង
៦. កែសំរួលបង្កើនប្រសិទ្ធភាពបទបញ្ញត្តិរបស់រដ្ឋាភិបាល និងកាត់បន្ថយបន្ទុកចំណាយនានានៅក្នុងការបង្កើត និងដំណើរការអាជីវកម្មខ្នាតតូចផ្សេងៗ ។

## ឯកសារយោង


Becker, Kristina Floodman (2004), *The Informal Economy* (Stockholm: Sida)

Chen, Martha Alter, Renana Jhabvala & Frances Lund (2002), *Supporting Workers in the Informal Economy: A Policy Framework* (Geneva: ILO)

Economic Institute of Cambodia (2006), *Decent Work in the Informal Economy in Cambodia: A Literature Review* (Bangkok: ILO)

Kusakabe, Kyoko (2006a), *On the Borders of Legality: A Review of Studies on Street Vending in Phnom Penh, Cambodia* (Bangkok: International Labour Office)

Kusakabe, Kyoko (2006b), *Policy Issues on Street Vending: An Overview of Studies in Thailand, Cambodia, and Mongolia* (Bangkok: International Labour Office)

Portes, Alejandro (1983), "The Informal Sector: Definition, Controversy, and Relation to National Development", *Review*, Volume 7, Number 1

## កំណត់សំគាល់

១ របាយការណ៍ស្រាវជ្រាវ មានចំណងជើង "លក់ដូរដើម្បីរស់ : អាជីវករផ្សារនៅទីរួមខេត្តកំពង់ចាម ប្រកបរបរចិញ្ចឹមជីវិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ" បានតាក់តែងចប់ក្នុងខែវិច្ឆិកា ២០០៨ ដោយសិក្ខាកាម និងក្រុម ADI ។ របាយការណ៍ជាពីរភាសា អង់គ្លេស និងខ្មែរនេះ មានចុះក្នុងវែបសាយ CCC/ADI ។

២ របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្ដីពីការលក់ដូរតាមដងផ្លូវនៅប្រទេសថៃ កម្ពុជា និងម៉ុងហ្គោលី បង្ហាញថា ការលក់ដូរតាមដងផ្លូវកើនឡើង ទាំងនៅពេលមានកំណើនសេដ្ឋកិច្ច និងមានវិបត្តិសេដ្ឋកិច្ច ។ នៅក្នុងអំឡុងពេលសេដ្ឋកិច្ចរីកដុះដាលលឿន ប្រជាជនកាន់តែច្រើនចូលប្រកបរបរនេះ ។ ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ការលក់ដូរក្លាយជាការងារដោះទ័លមួយគ្រា សំរាប់អ្នកគ្មានការងារធ្វើ (សូមមើល Kusakabe 2006b) ។

៣ នៅក្នុងឆ្នាំ២០០៤ នៅតំបន់ក្រុងផ្សេងទៀត បន្ទាត់ភាពក្រីក្រស្បៀងអាហារ និងបន្ទាត់ភាពក្រីក្រសំរាប់គ្រួសារទំហំមធ្យមត្រឹម ៥,៣នាក់ មានកំរិត ៨.៣១០រៀល និង ១០.៣៨៦រៀល ក្នុងមួយថ្ងៃរៀងគ្នា ។ សូមមើលប្រវត្តិស្ថានភាពភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៤ ផ្សព្វផ្សាយដោយក្រសួងផែនការ នៅខែកុម្ភៈ ២០០៦ ។

៤ Kusakabe (2006b) លើកឡើងថា ខុសប្លែកពីបុរស ពួកស្ត្រីមិនសូវមានសិទ្ធិគ្រប់គ្រងពេលវេលា និងការងាររបស់សមាជិកគ្រួសារទេ ។ ស្ត្រីលើកឡើងថា គឺកង្វះលទ្ធភាពទទួលបាន និងត្រួតត្រាលើការងារឥតបង់ថ្លៃ ហើយមិនមែនកង្វះជំនាញ ឬដើមទុនទេ ដែលធ្វើឱ្យមានភាពខុសគ្នាខ្លាំងរវាងស្ត្រី និងបុរស ក្នុងកំរិតលូតលាស់អាជីវកម្ម ។

៥ យោងតាមអនុក្រឹត្យស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ ដែលចុះហត្ថលេខានៅថ្ងៃទី១០ សីហា ១៩៩៤ ដោយនាយករដ្ឋមន្ត្រីទី១ និងទី២ ការលក់ដូរនៅតាមដងផ្លូវ ជាទូទៅ គឺជាសកម្មភាពខុសច្បាប់ ។ មាត្រា ១២ ចែងថា ការលក់ទំនិញ និងការធ្វើអោយរំខានដល់សណ្ដាប់ធ្នាប់សាធារណៈត្រូវបានហាមឃាត់ ។ ក្នុងករណីរំលោភបំពាន ជនល្មើសត្រូវផាកពិន័យចំនួន ១០.០០០រៀល ។ មាត្រា១៣ ចែងថា ការលក់ដូរទំនិញតាមរទេះតាមដងផ្លូវនានា ត្រូវបានហាមឃាត់ ។ ក្នុងករណីរំលោភបំពាន ជនល្មើសត្រូវផាកពិន័យចំនួន ២.០០០រៀល ។ ដោយគ្មានប៉ះពាល់ដល់ច្បាប់នេះ សៀវភៅបន្ទុកពន្ធភាសី បានចែងពីការប្រមូលពន្ធពីអ្នកជួលផ្ទះធំៗ ពីអ្នកលក់ដូរតាមកញ្ច្រែង និងអ្នកលក់តាមរទេះចល័ត ពោលគឺគ្រប់លក្ខណៈនៃការលក់ដូរ ។ ភាពផ្ទុយពីគ្នា រវាងច្បាប់ និងបទបញ្ញត្តិនេះ បង្កើតបានជាចន្លោះប្រហោងសំរាប់ការប្រមូលកម្រៃមិនច្បាស់លាស់ (សូមមើល Kusakabe 2006a) ។


## Cambodia Development Review—2009 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# អភិបាលកិច្ចមូលដ្ឋានលើធនធានទ្រព្យរួម: ករណីសិក្សាពីធារាសាស្ត្រនៅកម្ពុជា*

## សេចក្ដីផ្ដើម

ធនធានទ្រព្យរួម គឺជាធនធានដូចជា ព្រៃឈើ ត្រី ទឹក និងវាលស្មៅ ដែលពុំចាំបាច់ផលិតវាមកទេ និងជាប្រភពចម្បងនៃអាហារប្រចាំថ្ងៃ និងប្រាក់ចំណូលសម្រាប់ជនក្រីក្រនៅជនបទ ។ គេតែងយល់ថា ធនធានទាំងនេះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ដែលជាអង្គភាពមួយមើលមិនឃើញទេ និងដែលតាំងពីដើមរៀងមក បើតាមឯកសារជាតិ និងអន្តរជាតិនានា គឺជាស្ថាប័នអរូបីមួយដែលមិនបានគ្រប់គ្រងយ៉ាងសមស្រប ឬក៏មិនបានគ្រប់គ្រងទាល់តែសោះ នូវធនធានទាំងនេះ (Berkes ១៩៨៩) ។ ស្ថានភាពនេះធ្វើឱ្យកើតមានករណីទូទៅ ២ ។ ករណីទី១ គឺប្រជាពលរដ្ឋម្នាក់ៗ ហាក់ដូចជា មានសិទ្ធិប្រើប្រាស់ និងទាញយកផលពីធនធានទាំងនេះដោយសេរី និងគ្មានច្បាប់គ្រប់គ្រងអ្វីទេ (Ostrom ១៩៩០, ១៩៩២, ១៩៩៩) ។ ករណីទី២ គឺអ្នកមានទ្រព្យ និងមានអំណាច អាចប្រើប្រាស់ធនធានទាំងនេះ សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន និងថែមទាំងមិនអនុញ្ញាតអោយប្រជាជនក្រីក្រទាញយកផលអ្វីទៀតផង ។ ទោះជាករណីទី១ រឺករណីទី២ ក្ដី ក៏ជារឿយៗវានាំឱ្យធនធានត្រូវហិនហោច ឬបាត់បង់ទាំងស្រុង ។

ប្រទេសកម្ពុជាមានធនធានធម្មជាតិ យ៉ាងសំបូរ
និងកំពុងប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ច
ជាពិសេសជីវភាពរស់នៅរបស់ប្រជាជន
ប៉ុន្តែខ្វះខាតជាខ្លាំងនូវគោលនយោបាយដ៏ប្រសើរមួយ
សំរាប់គ្រប់គ្រងធនធានឱ្យមានចីរភាព
និងមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ។

ប្រទេសកម្ពុជា មានធនធានធម្មជាតិយ៉ាងសំបូរ និងកំពុងប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែខ្វះខាតជាខ្លាំងនូវគោលនយោបាយដ៏ប្រសើរមួយ សំរាប់គ្រប់គ្រងធនធានឱ្យមានចីរភាព និងមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ។ ដោយមើលឃើញពីតំរូវការនេះ កម្មវិធីអភិបាលកិច្ច នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានសម្រេចចិត្តធ្វើការសិក្សាលើចំនុចនេះ ដើម្បីស្វែងយល់ពីកត្តាផ្សេងៗ ដែលជួយសំរួល រឺរារាំងអភិបាលកិច្ចល្អលើធនធានទ្រព្យរួមនៅកម្ពុជា ជាពិសេសធនធានទឹក ដែលជាកត្តាស្នូលសំរាប់ការអភិវឌ្ឍន៍កសិកម្មនាពេលបច្ចុប្បន្ន ។

គម្រោងនេះបានសិក្សាលំអិតពីឌីណាមិក នៃវិធីសាស្ត្រពីរ ក្នុងការគ្រប់គ្រងទឹកស្រោចស្រព ។ វិធីសាស្ត្រទី១ គឺការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM) និងវិធីសាស្ត្រទី២ គឺវិមជ្ឈការក្នុងការគ្រប់គ្រងធនធានធម្មជាតិ (DNRM) ។ វិធីសាស្ត្រទាំងពីរនេះ ជាប់ទាក់ទងនឹងគោលនយោបាយថ្នាក់ជាតិពីរ គឺគោលនយោបាយទឹក និងវិមជ្ឈការ ។ ក្នុងគោលនយោបាយទឹក វិធីសាស្ត្រផ្អែកលើសហគមន៍ បានប្រគល់ការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រជាក់លាក់ណាមួយ ទៅឱ្យសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) តំណាងដោយសមាគមមួយមានថ្នាក់ដឹកនាំជ្រើសតាំងឡើងតាមការបោះឆ្នោត ចំណែកឯវិធីសាស្ត្រវិមជ្ឈការ បានផ្ដល់ឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាប់ឆ្នោត នូវសិទ្ធិគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនដីរបស់ខ្លួន រួមទាំងធនធានទឹកផង ។ ការសិក្សានេះ មានគោលបំណងស្វែងយល់ពី ស្ថានភាពក្នុងសហគមន៍មូលដ្ឋាន ដែលមានការអនុវត្តគោលនយោបាយ ឬការផ្ទេរមុខងារត្រួតស៊ីគ្នាទាំងពីរនេះ ។ ការសិក្សាស្រាវជ្រាវនេះបានចោទសួរថា តើវិធីសាស្ត្រនីមួយៗ ជះឥទ្ធិពលដោយឯករាជ្យយ៉ាងដូចម្ដេចទៅលើការគ្រប់គ្រងទឹកស្រោចស្រពក្នុងមូលដ្ឋាន ហើយអន្តរកម្មនៃវិធីសាស្ត្រទាំងពីរ វារួមចំណែកយ៉ាងដូចម្ដេចក្នុងការងារគ្រប់គ្រងទាំងមូល ។

ការសិក្សានេះ មានគោលបំណងសំខាន់ៗពីរ: ១. សិក្សាពីដំណើរការដើម្បីកំណត់ពីផលប៉ះពាល់ខាងគោលនយោបាយ និងលើកជាអនុសាសន៍ និង ២. រួមចំណែកកសាងឯកសារ ស្ដីពីអភិបាលកិច្ចធនធានទ្រព្យរួម ។

## វិធីសាស្ត្រស្រាវជ្រាវ

ផ្អែកលើគោលបំណងនៃការសិក្សា អ្នកស្រាវជ្រាវបានសិក្សាលើឯកសារជាតិ និងអន្តរជាតិ ដើម្បីកំណត់នូវ អថេរនានាដែលត្រូវពិនិត្យតាមដានដល់មូលដ្ឋាន ។ បន្ទាប់មក អ្នកស្រាវជ្រាវត្រូវប្រៀបធៀបក្របខ័ណ្ឌការសិក្សាដែលទទួលបានពីការសិក្សាឯកសារ ទៅនឹងទិន្នន័យអង្កេតនៅកន្លែង ។ សហគមន៍កសិករធ្វើស្រែប្រាំង ដែលពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រមួយក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានជ្រើសរើសជា ករណីសិក្សានៃការគ្រប់គ្រងទឹកស្រោចស្រពក្នុងមូលដ្ឋាន តាំងតែពីពេលរបបខ្មែរក្រហមបានដួលរលំមក ។

## លទ្ធផលសំខាន់ៗ

ករណីសិក្សាបានបង្ហាញថា វិធីសាស្ត្រ DNRM ត្រូវបានអនុវត្តនៅកម្ពុជាតាំងពីចុងទសវត្សរ៍ ១៩៨០ និងដើមទសវត្សរ៍ ១៩៩០ ។ ទោះបីដោយថៃដន្យ ឬដោយការរៀបចំក្ដី ក៏ការគ្រប់គ្រងធារាសាស្ត្រ គឺជាការទទួលខុសត្រូវរបស់មេឃុំ ដែលទទួលបានជំនួយបច្ចេកទេស និងធនធានអភិវឌ្ឍន៍

---

* ដោយអ្នកស្រី ជា ជូ ជាអ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ អត្ថបទនេះ សង្ខេបនូវលទ្ធផលនៃគម្រោងស្រាវជ្រាវមួយក្នុងកម្មវិធីកែច្នៃរបស់ផ្នែកអភិបាលកិច្ចនៃ វបសអ ។ អត្ថបទសិក្សាទាំងមូលលើប្រធានបទនេះ នឹងមានចុះនៅលើវេបសាយរបស់ វបសអ នាពេលឆាប់ៗនេះ ។

ខ្លះពីមន្ទីរខេត្ត និងដែលមានភារកិច្ចប្រមែប្រមូលប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីកសាងសំណង់គ្រប់គ្រងទឹក និងជួយត្រួតពិនិត្យការសាងសង់ និងការគ្រប់គ្រង ។ ករណីសិក្សាបានបង្ហាញថា តួអង្គរដ្ឋអំណាចនៅមូលដ្ឋានដែលសំខាន់ៗជាងគេ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនៅអំឡុងពេលនេះ រួមមាន មេឃុំ មេភូមិ និងភ្នាក់ងារពង្រឹងអនុវត្តន៍ច្បាប់ ។ ទោះបីជាការគ្រប់គ្រងនៅពេលនេះ បង្ហាញពីលក្ខណៈមជ្ឈការនៃប្រព័ន្ធរដ្ឋ ប៉ុន្តែឃុំមិនអាចគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពឡើយ ពីព្រោះឃុំមិនមានធនធានផ្ទាល់ និងជាប់រវល់កិច្ចការនយោបាយ ដូចជាការប្រមូលប្រជាពលរដ្ឋឱ្យចូលបម្រើក្នុងកម្មវិធីក៥ ជាដើម ។

ដើម្បីឆ្លើយតបនឹងសំណើរបស់ សហគមន៍អ្នកផ្ដល់ជំនួយដែលក្ដោបក្ដាប់ទឹកប្រាក់អភិវឌ្ឍន៍នៅទសវត្សរ៍ ១៩៩០ មានការផ្លាស់ប្ដូរពី DNRM ទៅរក CBNRM ដោយមានសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) ត្រូវបានកំណត់ចេញជាផ្លូវការ និងសមាគមក្នុងមូលដ្ឋានមួយដែលរដ្ឋរឺអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំឡើង ដើម្បីធ្វើជាតំណាងរបស់សហគមន៍ ។ វិធីសាស្ត្រ CBNRM ដែលមានខ្សែរយៈគ្រប់គ្រងពីលើចុះក្រោមនេះ ត្រូវបានផ្សព្វផ្សាយទូទាំងប្រទេសនៅចុងទសវត្សរ៍ ១៩៩០ នៅពេលគោលនយោបាយអភិវឌ្ឍន៍ និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួមត្រូវបានអនុម័តនៅថ្នាក់ជាតិ ។

តាំងពីដើមឆ្នាំ២០០២ ការគ្រប់គ្រងទឹកស្រោចស្រពនៅមូលដ្ឋាន បានប្រើជាមួយគ្នានូវ CBNRM និង DNRM ហើយទាំងពីរនេះ បានដាក់បញ្ចូលជាផ្លូវការទៅក្នុងគោលនយោបាយជាតិគ្រប់គ្រងវិស័យនេះ ។

**ទោះបីជាការគ្រប់គ្រងនៅពេលនេះ បង្ហាញពីលក្ខណៈមជ្ឈការនៃប្រព័ន្ធរដ្ឋ ប៉ុន្តែឃុំមិនអាចគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពឡើយ ពីព្រោះឃុំមិនមានធនធានផ្ទាល់ និងជាប់រវល់កិច្ចការនយោបាយ ។**

### ការរួមចំណែកនៃ CBNRM

ក្នុងវិធីសាស្ត្រនេះ អភិបាលកិច្ចល្អមានលក្ខណៈសំគាល់ពីរ ។ ទីមួយ គឺ FWUC មានលក្ខណៈឆ្លើយតបល្អជាងប្រព័ន្ធរដ្ឋ ចំពោះតម្រូវការអភិវឌ្ឍន៍របស់សហគមន៍មូលដ្ឋាន ។ ជាក់ស្ដែង FWUC បានពង្រីកប្រព័ន្ធធារាសាស្ត្រតាមរយៈការកសាងស្ពាន និងផ្លូវទៅកាន់ទ្វារទឹក ដើម្បីសម្រួលដល់ការដឹកជញ្ជូនស្រូវ ដែលចោទបញ្ហាជាច្រើនទសវត្សរ៍មកហើយៗ ដែលអាជ្ញាធរមូលដ្ឋានមិនបានដោះស្រាយ ។ ទីពីរ គឺ FWUC អាចរកឃើញបញ្ហាយ៉ាងឆាប់ និងផ្ដល់ដំណោះស្រាយទាន់ពេល ដូចជានៅពេលចាត់ចែងការកសាងផ្លូវឆ្លងកាត់ដីរបស់កសិករជាច្រើននាក់នៅក្នុងមូលដ្ឋាន ។ សហគមន៍បានកត់សម្គាល់យ៉ាងឆាប់នូវ បញ្ហាកសិករមិនព្រមលះបង់ដីដោយគ្មានសំណង ។ ដូច្នេះ FWUC ក៏បានលើកសំណើទៅឃុំឱ្យយកដីឃុំខ្លះទៅដោះដូរជាមួយកសិករ ដើម្បីអាចដំណើរការសាងសង់ផ្លូវ ដែលអាចជួយដោះស្រាយបញ្ហាដឹកជញ្ជូនស្រូវសំរាប់សហគមន៍ទាំងមូល ។ ទោះបីគំនិតផ្ដួចផ្ដើមរបស់សហគមន៍មិនបានផ្ដល់ដំណោះស្រាយភ្លាមៗ សំរាប់បញ្ចប់បញ្ហាក្ដី ប៉ុន្តែករណីនេះបានបង្ហាញថា FWUC មានការយល់ដឹង និងចំណេះដឹងយ៉ាងទូលំទូលាយពីបរិបទនៅមូលដ្ឋាន ។

### *ការរួមចំណែកនៃ DNRM*

តាំងពីពេលចាប់អនុវត្ត CBNRM មក តួនាទីរបស់រដ្ឋអំណាចមូលដ្ឋានត្រូវបានកាត់បន្ថយមកត្រឹមអន្តរាគមន៍ផ្សេងៗ តាមការស្នើសុំរបស់ FWUC (ឧទាហរណ៍ នៅពេលមានវិបត្តិ ដូចជាកង្វះទឹកនៅដើមឆ្នាំ២០០៦ និងដើមឆ្នាំ២០០៧) ។ ស្ថានភាពនេះនៅដដែល ទោះបីគោលនយោបាយវិមជ្ឈការនៅឆ្នាំ ២០០២ បានផ្ដល់សិទ្ធិអំណាចជា រដ្ឋអំណាចឯករាជ្យថ្នាក់មូលដ្ឋានទៅដល់ក្រុមប្រឹក្សាឃុំសង្កាត់ក៏ដោយ ។ ជាទូទៅ ទោះបីគេចាត់ទុកឃុំជាអង្គភាពមូលដ្ឋាន ដែលមានអំណាចគ្រប់គ្រាន់អាចបញ្ជាឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រតិបត្តិតាមបានក្ដី ប៉ុន្តែការគ្រប់គ្រងទឹកស្រោចស្រពស្ថិតក្រោមការក្ដោបក្ដាប់របស់ FWUC ដោយមានការគាំទ្រម្ដងម្កាល គឺក្រោមរូបភាពជាការជួយធ្វើអន្តរាគមន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ ។

### កត្តារាំងរាំង និងកត្តាជំរុញដល់អភិបាលកិច្ចមូលដ្ឋានលើធនធានទូទៅរួមនាពេលបច្ចុប្បន្ន

គេបានរកឃើញកត្តាគន្លឹះចំនួនបីដែលមានឥទ្ធិពលលើការគ្រប់គ្រងទឹក ស្រោចស្រពនៅមូលដ្ឋាន គឺមានការចូលរួមរបស់សហគមន៍ភាពជាម្ចាស់របស់សហគមន៍ និងសិទ្ធិអំណាច ឬការត្រួតត្រារបស់សហគមន៍ ។

ការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងការងារសហគមន៍ ដែលជាយន្តការគន្លឹះជំរុញជោគជ័យនៃដំណើរការ CBNRM វាមានកំរិតនៅឡើយនៅក្នុងតំបន់សិក្សា ។ រឿងនេះ ដែលឃើញមានដំណើរការម្ដងម្កាលដែរនៅក្នុងសហគមន៍ សព្វថ្ងៃត្រូវរាំងស្ទះដោយកត្តាជាច្រើន ។ ទីមួយ គឺដំណើរការបែបពីលើចុះក្រោមនៃ CBNRM មិនទាន់អនុវត្តបានពេញលេញទេនូវការងាររៀបចំសហគមន៍ និងផ្ដល់សិទ្ធិអំណាច ។ វិធីសាស្ត្រផ្ដួចផ្ដើមឡើងដោយរដ្ឋនេះ ដំបូងឡើយសង្កត់ធ្ងន់លើការបង្កើតសមាគមតាមរយៈការបោះឆ្នោតមួយដង ដោះស្រាយបានសព្វគ្រប់[1] ដើម្បីតំណាងឱ្យសហគមន៍ និងការបណ្ដុះបណ្ដាលថ្នាក់ដឹកនាំ ២-៣នាក់ ក្នុងសហគមន៍ពីវិធីសាស្ត្រ CBNRM និងពីវិធីដំណើរការសមាគម ។ ការអនុវត្តបែបនេះបានបំភ្លេចចោលនូវសារៈសំខាន់នៃការផ្ដល់សិទ្ធិអំណាច ឱ្យសមាជិកសហគមន៍ ដែលជាកត្តាស្នូលសំរាប់ដំណើរការនេះ ដើម្បីឱ្យគេយល់ដឹងពី

១ គេសង្កេតឃើញថា មានការបោះឆ្នោតក្នុងសហគមន៍តែមួយលើកប៉ុណ្ណោះនៅឆ្នាំ២០០០ ហើយតាំងពីពេលនោះមក សមាគមមិនដែលបានបន្តអាណត្តិ៣ឆ្នាំ របស់ខ្លួនទៀតទេ ។

សិទ្ធិអំណាចរបស់ខ្លួន ហើយចូលរួមក្នុងការកសាងបទបញ្ញត្តិផ្សេងៗ ការអនុវត្តបទបញ្ញត្តិ និងការពង្រឹងអនុវត្តបទបញ្ញត្តិនៅក្នុងសហគមន៍ ញ៉ាំងឱ្យដំណើរការមានការយកចិត្តទុកដាក់ខ្ពស់ ដល់បញ្ហាគណនេយ្យភាពពីលើចុះក្រោមនៅក្នុងសមាគម ។ កសិករភាគច្រើនក្នុងសហគមន៍ នៅតែគិតឃើញបែបបុរាណពីការចូលរួម ពោលគឺគ្រាន់តែទៅចូលរួមក្នុងការប្រជុំផ្សេងៗ និងបង់ថ្លៃប្រើទឹកស្រោចស្រពប៉ុណ្ណោះ ដោយគ្មានការលើកឡើងពីចំណុចព្រួយបារម្ភ រឺការទាមទារឱ្យមានដំណោះស្រាយអ្វីទេ ។

ទីពីរ កង្វះការផ្តល់សិទ្ធិអំណាចឱ្យសហគមន៍ ធ្វើឱ្យសហគមន៍ពុំមានយន្តការជាផ្លូវការសំរាប់ទទួលបណ្តឹងតវ៉ា ដូច្នេះហើយការយល់ច្រឡំពីគ្នាក៏កើនឡើងរវាងពួកកសិករ ហើយនឹងសមាគមជាតំណាងរបស់ខ្លួន ។ ក្នុងករណីសិក្សានេះ ជារឿយៗកសិករប្រើពាក្យចចាមអារាម រឺបញ្ចិតបញ្ចៀងដើម្បីតវ៉ាពីអ្នកដឹកនាំសមាគម និងចំណុចខ្វះខាតផ្សេងៗក្នុងបុគ្គលិកលក្ខណៈរបស់ពួកគេ ដែលខាងសមាគមយល់ថាជារឿងគួរឱ្យក្តៅក្រហាយ ហើយភាគីទាំងពីរដែលត្រូវជិតស្និទ្ធនឹងគ្នា ក៏បែរជាកាន់តែចុះខ្សោយទំនាក់ទំនង ។ នៅក្នុងសហគមន៍ គេសង្កេតឃើញមានការមិនទុកចិត្តគ្នា និងស្មារតីរួមរួមគ្នាក៏រិតខ្សោយ ។ ប្រជាជនក្នុងមូលដ្ឋានមើលឃើញការតែងតាំងសមាជិកភាគច្រើនក្នុងក្រុមអ្នកប្រើប្រាស់ទឹកថាជាការប្រកាន់បក្សពួករបស់ថ្នាក់ដឹកនាំសមាគម ដែលបានដាក់បញ្ចូលសាច់ញាតិ និងមិត្តភក្តិខ្លួន ដើម្បីរកផលចំណេញ ។

ទីបី សហគមន៍ដែលមានស្ថាប័នខ្សោយដូចក្នុងករណីសិក្សានេះ អាចទទួលជោគជ័យ រឺបរាជ័យដោយសារជាសំខាន់របៀបដឹកនាំរបស់អ្នកដឹកនាំសំខាន់ៗ ជាពិសេសនៅពេលដែលរដ្ឋអំណាចមូលដ្ឋាន និងមន្ទីរក្រសួងជំនាញ មិនសូវបានពាក់ព័ន្ធនឹងការងាររបស់សមាគម និងជួយត្រួតពិនិត្យភាពពេញច្បាប់ និងប្រសិទ្ធភាពការងាររបស់សមាគម ។ ក្នុងករណីសិក្សានេះ ថ្នាក់ដឹកនាំសមាគមមានរបៀបដឹកនាំ ដូចជា មេកើយមិនចង់ចែករំលែកភារកិច្ច មិនធ្វើសេចក្តីសំរេច ដោយផ្អែកលើការមូលមតិ ប៉ុន្តែច្រើនតែអនុវត្តតាមផែនការដែលខ្លួនឯងរៀបចំជាមុន ប្រើប្រាស់អង្គប្រជុំ និងសមាជិកបំរើការឯទៀតៗ ជាឈ្នាន់សំរាប់ការពារ និងអនុវត្តគំនិតខ្លួន ទុកចំណូលទាំងអស់នៅនឹងខ្លួនឯង ហើយសំរេចអារកាត់លើចំណាយទាំងអស់ដែលខ្លួនយល់ថា មានប្រយោជន៍សំរាប់សហគមន៍ ។ របៀបធ្វើការនេះ មាននិន្នាការគួរឱ្យបារម្ភ និងចោទបញ្ហាពីភាពពេញច្បាប់ និងចីរភាពនៃ CBNRM នៅក្នុងសហគមន៍ ។

ភាពជាម្ចាស់ ដែលជាកត្តាមួយសំខាន់បំផុតសំរាប់ជំរុញ CBNRM ក៏អនុវត្តមិនទាន់បានពេញលេញដែរ ។ គេអង្កេតឃើញមានភាពជាម្ចាស់ពីរប្រភេទនៅក្នុងករណីសិក្សា គឺអារម្មណ៍ជាម្ចាស់លើធនធាន និងអារម្មណ៍ជាម្ចាស់លើសមាគម FWUC ។ ក្នុងសហគមន៍ ភាពជាម្ចាស់លើធនធានអាចមើលឃើញតាមបែបបទប្រជាកសិករគោរព ភ្នំខ្សាច់ ដែលត្រូវបាន

**បញ្ហាចោទពីរបៀបធ្វើការរបស់សមាគម ឬថ្នាក់ដឹកនាំ ដែលមិនបានឱ្យសមាជិកពាក់ព័ន្ធចូលរួមទាំងអស់គ្នា ក្នុងការងារធ្វើផែនការរបស់សមាគម បានកាត់បន្ថយអារម្មណ៍ជាម្ចាស់ ហើយស្ថានភាពនេះ បានគំរាមកំហែង ដល់ការចូលរួមនៅថ្នាក់មូលដ្ឋាន ។**

កសាងឡើងនៅក្បែរស្ពាន ដោយប្រើប្រាក់កាសរបស់សហគមន៍ ដើម្បីជានិមិត្តរូបនៃបារមីសក្តិសិទ្ធិរបស់អាងទឹក ។ ប៉ុន្តែ ប្រជាកសិករមិនមានអារម្មណ៍ជាម្ចាស់លើសមាគម FWUC ទេ ដោយមើលឃើញថា គ្រាន់តែជាអំណាចគ្រប់គ្រងមួយស្រទាប់ទៀត និងជាអភិបាលកិច្ចមិនល្អតែប៉ុណ្ណោះ ។ ក្នុងការបោះឆ្នោតនៅឆ្នាំ២០០០ ពួកកសិករជាប់ពាក់ព័ន្ធមិនបានចូលរួមទាំងអស់គ្នាទេ ហើយតាំងពីពេលនោះ មកមានកសិករជាច្រើននាក់ទៀតបានចូលមកក្នុងសហគមន៍ ដោយមិនដែលមានឱកាសបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំរបស់ខ្លួនឡើយ ។

បញ្ហាចោទពីរបៀបធ្វើការរបស់សមាគម ឬថ្នាក់ដឹកនាំ ដែលមិនបានឱ្យសមាជិកពាក់ព័ន្ធចូលរួមទាំងអស់គ្នា ក្នុងការងារធ្វើផែនការរបស់សមាគមបានកាត់បន្ថយអារម្មណ៍ជាម្ចាស់ ហើយស្ថានភាពនេះ បានគំរាមកំហែងដល់ការចូលរួមនៅថ្នាក់មូលដ្ឋាន ។ ដោយគ្មានអារម្មណ៍ជាម្ចាស់លើសមាគមប្រជាកសិករមិនបានចាត់ទុកសមាគម ជាស្ថាប័នពេញច្បាប់សំរាប់គ្រប់គ្រងប្រព័ន្ធស្រោចស្រពឡើយ ។ ពួកគេយល់ថា ទឹកស្រោចស្រព គឺជាទ្រព្យសាធារណៈ ដូច្នេះមិនគួរស្ថិតក្រោមការគ្រប់គ្រងរបស់សមាគមជាក់លាក់ណាមួយទេ ឬក៏និយាយម្យ៉ាងទៀតថា គ្មានសមាគមណាអាចទាមទារកម្មសិទ្ធិលើប្រព័ន្ធស្រោចស្រព និងសម្រេចអារកាត់លើសិទ្ធិប្រើប្រាស់ និងថ្លៃសេវាលើធនធានទាំងនេះឡើយ ។ ចំពោះប្រជាកសិករ ការគ្រប់គ្រងធនធាន គឺជាភារកិច្ចនៃភ្នាក់ងាររបស់រដ្ឋ ហើយការពង្រឹងអនុវត្តច្បាប់ គឺជាភារកិច្ចរបស់ស្ថាប័ន ដូចជាខាងនគរបាល និងយោធាជាដើម ។ សហគមន៍ពីរដែលមានធនធាន និងមានប្រព័ន្ធធារាសាស្ត្រពីរនៅជាប់គ្នា និងនៅក្នុងដែនរងតែភ្លៀងតែមួយ ហាក់ដូចមិនព្រមទទួលស្គាល់ពីវត្តមាន និងតួនាទីរបស់ភាគីម្ខាងទៀតទេ ដូច្នេះសូម្បីតែសកម្មភាពតូចតាច ដូចជា កិច្ចចរចាគ្នាពីការប្រើទឹក ក៏រំពឹងថាត្រូវដោះស្រាយតាមរយៈរចនាសម្ព័ន្ធ អភិបាលកិច្ចនៅមូលដ្ឋានដែរ (ក្នុងករណីនេះ គឺតាមរយៈមេឃុំ) ។

ក្នុងករណីសិក្សានេះ ហាក់ដូចមានការតម្រង់ទិសមួយដែលអនុញ្ញាតឱ្យសមាគម FWUC (គឺមិនមែនសហគមន៍ទេ) ធ្វើការត្រួតត្រាលើធនធានដោយខ្លួនឯង ដោយគ្មាន ឬមានការគាំទ្រ/ការពិនិត្យតាមដានពីស្ថាប័នរដ្ឋ ។ មកដល់ពេលនេះ សមាគមបានបង្ហាញពីអសមត្ថភាពក្នុងការត្រួតត្រាលើធនធាន ដូចជាការត្រួតត្រាលើសិទ្ធិប្រើប្រាស់ជាដើម ។ ទោះបីសមាគមមានអាណត្តិគ្រប់គ្រងសិទ្ធិប្រើប្រាស់ក្តី ប៉ុន្តែលទ្ធភាពរបស់សមាគមក្នុងការអនុវត្តសិទ្ធិនេះនៅទន់ខ្សោយណាស់ ។ Ostrom (១៩៩៩) បានលើកមតិថា ការគ្រប់គ្រងធនធានទ្រព្យរួមប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានលទ្ធភាពត្រួតត្រាលើសិទ្ធិប្រើប្រាស់ ព្រោះវាជាប់ទាក់ទងដោយផ្ទាល់ទៅដល់សុខុមាលភាព និងនៃធនធាន ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រង ។

ប៉ុន្តែករណីនេះ មិនឃើញមានក្នុងករណីសិក្សាឡើយ ។ តាមរបាយការណ៍របស់មន្ទីរជំនាញខេត្ត ផ្ទៃគ្របដណ្តប់នៃប្រព័ន្ធធារាសាស្ត្រ ត្រូវបានពង្រីកធំហួសសមត្ថភាពរបស់ប្រព័ន្ធនោះច្រើនណាស់ ប៉ុន្តែគ្មានឃើញធ្វើអ្វីសោះដើម្បីដោះស្រាយបញ្ហានេះ ។ សមាជិកសមាគម ឬប្រជាកសិករ មិនបានយល់ដឹងច្បាស់ពីអាណត្តិរបស់សមាគមទេ ហើយបញ្ហានេះរឹតតែធ្ងន់ធ្ងរទៀត ដោយ FWUC នាបច្ចុប្បន្ន បានធ្វើសកម្មភាពលើសពីភារកិច្ចពេញច្បាប់ ហើយប្រជាកសិករចេះតែចោទសួរពីភាពពេញច្បាប់របស់ FWUC ទោះបីកសិករភាគច្រើននៅតែបង់ថ្លៃសេវាផ្តល់ទឹកក្តី ។ កង្វះលទ្ធភាពត្រួតត្រាសិទ្ធិប្រើប្រាស់ បណ្តាលឱ្យមានវិសមភាពរវាងធនធាន និងការិតប្រើប្រាស់ ហើយវាប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍជីវភាពរយៈពេលវែងរបស់សហគមន៍ និងវត្តមានធនធានទៅអនាគត ។ កង្វះទឹក នៅពាក់កណ្តាល ឬនៅចុងរដូវដាំដុះគ្មានអ្វីប្លែកទេ ហើយនៅពេលខ្វះទឹក បទបញ្ញត្តិរបស់សហគមន៍ដែលទន់ខ្សោយស្រាប់នោះ ត្រូវបានបំភ្លេចចោលតែម្តង ហើយការប៉ះទង្គិចពាក្យសំដីរវាងកសិករលើបញ្ហាទឹក បានធ្វើឱ្យល្អក់កករដល់ទំនាក់ទំនងក្នុងសហគមន៍ ។ ជាមួយគ្នានោះ ក៏មានសំណង់ធារាសាស្ត្រនៅខ្សែទឹកខាងលើ ដែលមានដំណើរការប៉ះពាល់ដល់ CBNRM នៅក្នុងសហគមន៍សិក្សា ។

ដំណោះស្រាយ គឺអាចជាការបង្កើតយន្តការមួយសំរាប់ជួយអោយសហគមន៍ទាំងអស់ ដែលប្រើប្រាស់ទឹកក្នុងដែនរងទឹកភ្លៀងតែមួយ អាចចែករំលែកព័ត៌មាន ដើម្បីបានដឹងពីសកម្មភាពរបស់ភាគីនីមួយៗ ។ Kim & Öjendal (២០០៧) បានបញ្ជាក់ថា យន្តការនេះនៅឆ្ងាយពីការពិតខ្លាំងណាស់ ដោយសារកង្វះការយល់ដឹងពីតម្រូវការយន្តការ កង្វះធនធាន និងកង្វះអាណត្តិតាមផ្លូវច្បាប់ ។

## សេចក្តីបញ្ចប់

ករណីសិក្សាបង្ហាញថា អភិបាលកិច្ចលើទឹកស្រោចស្រពនៅមូលដ្ឋាននាពេលបច្ចុប្បន្ន គឺអនុវត្តតាមវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM) ក្នុងបរិបទនៃ វិមជ្ឈការក្នុងការគ្រប់គ្រងធនធានធម្មជាតិ (DNRM) ។ តាំងពីពេលរបបខ្មែរក្រហមបានដួលរលំមក រដ្ឋអំណាចមូលដ្ឋានជារឿយៗ អាចលើកសំណើដល់ថ្នាក់លើឱ្យផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ ដើម្បីធ្វើវិនិយោគតែមួយលើក ជាសំណង់ធារាសាស្ត្រ ប៉ុន្តែក្រោយបានសាងសង់រួចរាល់ ខាងរដ្ឋអំណាចទាំងថ្នាក់មូលដ្ឋាន និងទាំងថ្នាក់លើ ច្រើនតែដកខ្លួនចេញបាត់ ធ្វើឱ្យសំណង់មិនអាចដំណើរការមានចីរភាព ។ វិធីសាស្ត្រ CBNRM ដូចកំពុងអនុវត្តសព្វថ្ងៃ អាចជួយបំពេញចន្លោះខ្វះខាតទាំងនេះបាន ពីព្រោះវាអាចឆ្លើយតបប្រសើរជាងទៅនឹងតម្រូវការនៅមូលដ្ឋាន ចាត់ចែងបញ្ហាបានឆាប់រហ័ស និងផ្តល់ដំណោះស្រាយអស់ចំណាយតិច និងសមស្របតាមបរិបទ ។ ប៉ុន្តែវិធីសាស្ត្រនេះអនុវត្តបានតិចនៅឡើយ ដោយសារយន្តការជំរុញទាំងបី គឺ ការចូលរួម ភាពជាម្ចាស់ និងការត្រួតត្រា មិនទាន់ដំណើរការបានពេញលេញ ។ លោក Carlson (២០០៣) បានលើកថា គេត្រូវធ្វើការបីយ៉ាង ដើម្បីប្រើប្រាស់អំណាចនៃយន្តការទាំងបី ។ ទីមួយ បទបញ្ញត្តិច្បាប់គួរផ្តល់សិទ្ធិអំណាចដល់សហគមន៍ ដោយកំណត់ទំហំសិទ្ធិរបស់សហគមន៍លើទ្រព្យរបស់សហគមន៍ ។ ទីពីរ ត្រូវធានាថាមានការគាំទ្រពីខាងក្រៅដ៏ល្អបំផុតដល់សមាគម និងសហគមន៍ ដូចជា ខាងផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ។ ទីបី ត្រូវកសាងទំនុកចិត្តក្នុងសហគមន៍ និងរវាងសហគមន៍ និងរដ្ឋាភិបាល ។ ក្នុងការអនុវត្តរបស់សមាគម FWUC និងសហគមន៍ក្នុងករណីសិក្សាសមាសធាតុទាំងបីនេះនៅខ្វះខាត ហើយគេត្រូវដោះស្រាយរឿងនេះ ដើម្បីកែលំអអភិបាលកិច្ចនៅមូលដ្ឋានលើទឹកស្រោចស្រព ។

## ឯកសារយោង


Berkes, F. (1989), *Common property resources: Ecology and community-based sustainable development* (London: Belhaven Press)

Carlsson, L. (2003), "The Strategy of the Commons: History and Property Rights in Central Sweden", in, F. Berkes, J. Colding & E. Folke (eds.), *Navigating Social-Ecological Systems: Building Resilience for Complexity and Change* (New York: Cambridge University Press)

Hardin, G. (1968), "The tragedy of the commons", *Science*, 162, pp. 1243–1248

Kim S. & J. Öjendal (2007 ), *Where decentralisation meets democracy: Civil society, local government and accountability in Cambodia*, Working Paper 35 (Phnom Penh: CDRI)

Ostrom, E. (1990), *Governing the commons: The evolution of institutions for collective action* (New York: Cambridge University Press)

Ostrom, E. (1992), *Crafting Institutions for Self-Governing Irrigation Systems* (San Francisco: ICS Press)

Ostrom, E. (1999), "Institutional rational choice: An assessment of the institutional analysis and development framework", in P.A. Sabatier (ed.), *Theories of the Policy Process* (Boulder: Westview Press) pp. 35–71

Shaw-Lefevre, E.G. (1894), *English commons and forests: The story of the battle during the last thirty years for public rights over the commons and forests of England and Wales* (London: Cassel)

Yin R.K. (2003), *Applications of case study research* (London: Sage Publications)

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅសហរដ្ឋអាមេរិកមានអត្រា -៣,៩% ធៀបនឹង ២,៨% ក្នុងត្រីមាសទី២ ឆ្នាំ២០០៨ ។ ការធ្លាក់ចុះគួរឱ្យកត់សម្គាល់នេះ បណ្ដាលជាសំខាន់ពីការរួមចំណែកអវិជ្ជមាន នៃវិនិយោគលើសារពើភ័ណ្ឌឯកជន ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន និងការនាំចេញ ប៉ុន្តែមានការប៉ះប៉ូវមួយផ្នែកវិញ ដោយការរួមចំណែកវិជ្ជមាននៃចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ និងចំណាយរបស់រដ្ឋ និងរដ្ឋបាលមូលដ្ឋាន ។ ក្នុងត្រីមាសនេះដែរ កំណើនផលិតផលពិតប្រចាំឆ្នាំនៅតំបន់អឺរ៉ូ មានអត្រា -៤,៨% ហើយមូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺការធ្លាក់ចុះខ្លាំងនៃការបង្កើតទ្រព្យមូលធនជាប់លាប់ដុល (-១១,៤%) និងការនាំចេញ (-១៧,៧%) ប៉ុន្តែមានការប៉ះប៉ូវវិញ ដោយសារកំណើនចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល ២,៥% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន ។ កំណើន ផសស ពិត នៅជប៉ុន កើនឡើងវិញដល់ ០,៦% បន្ទាប់ពីបានរួមចុះ ៩,១% នៅត្រីមាសមុន ហើយកត្តាសំខាន់អាចជា ការងើបឡើងវិញនៃការនាំចេញ ការបញ្ជាទិញគ្រឿងចក្រ និងផលិតផលឧស្សាហកម្ម ។

កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅចិន ឡើងខ្ពស់ដល់ ៧,៩% ធៀបនឹង ៦,១% នៅត្រីមាសទី១ ឆ្នាំ២០០៩ ដោយសារកំណើនខ្លាំងក្នុងវិស័យសេវាកម្ម និងកម្មន្តសាល ។ ការងើបសេដ្ឋកិច្ចអាចមើលឃើញច្បាស់នៅហុងកុង ក្នុងត្រីមាសទី២ ដោយ ផសស ពិត មានអត្រាកំណើន -៣,៨% ធៀបនឹង -៧,៨% នៅត្រីមាសមុន ។ ការងើបឡើងវិញនេះ បណ្ដាលពីចំណាយប្រើប្រាស់ដែលបានល្អប្រសើរឡើង ប៉ុន្តែវាមានល្បឿនយឺត ដោយសារចំណាយវិនិយោគមានតិចតួច និងបានធ្លាក់ចុះ ១៤% ធៀបនឹងកាលពីមួយឆ្នាំមុន។ នៅកូរ៉េខាងត្បូងក៏មាននិន្នាការប្រហាក់ប្រហែលគ្នា ដោយចំណាយជាមូលធនបានក្លាយជាវិជ្ជមានវិញ ហើយការនាំចេញទំនិញកើន ១៤% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅតៃវ៉ាន់ បានធ្លាក់ចុះនៅត្រីមាសទី២ ឆ្នាំ២០០៩ ប៉ុន្តែមិនធ្ងន់ធ្ងរដូចក្នុងត្រីមាសទី១ ទេ ហើយការប្រសើរឡើងបន្តិចម្ដងៗនេះបណ្ដាលជាសំខាន់ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុកកាន់តែមានច្រើន និងកំណើនលឿននៃការនាំចេញទំនិញ និងសេវា ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ទិន្នន័យ ផសស នៅម៉ាឡេស៊ី បង្ហាញពីស្ថានភាពសេដ្ឋកិច្ចដែលមានស្ថិរភាពឡើងវិញ និងអត្រារួមចុះពីមួយឆ្នាំទៅមួយឆ្នាំមានកំរិតទាបជាងនៅត្រីមាសមុន ដែលបណ្ដាលជាសំខាន់ដោយសារការនាំចេញទំនិញ និងសេវាកម្មមានកំណើនខ្លាំង (៥,៤%) និងកំណើនការបង្កើតទ្រព្យមូលធនជាប់លាប់ (៩,៧%) ។ នៅត្រីមាសទី២ នេះ សេដ្ឋកិច្ចរបស់ ថៃ និងសិង្ហបុរី ក៏មានសញ្ញាងើបឡើងវិញខ្លះៗដែរ ។ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរី គឺ -៣,៥% ដោយសារ ចំណាយប្រើប្រាស់ឯកជន ចំណាយវិនិយោគសហគ្រាស និងការនាំចេញសុទ្ធនូវទំនិញ និងសេវា បានល្អប្រសើរឡើង ។ នៅត្រីមាសទី២ ថៃមានការរួមចុះសេដ្ឋកិច្ចយឺតជាងមុន ដោយសារការធ្លាក់ចុះយឺតជាងមុន នៃចំណាយប្រើប្រាស់ក្នុងគ្រួសារ និងចំណាយវិនិយោគ និងការរួមចំណែកវិជ្ជមានយ៉ាងតូចមួយរបស់រដ្ឋាភិបាលនៅក្នុងចំណាយប្រើប្រាស់។

## អតិផរណាក្នុងពិភពលោក និងអត្រាការប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០០៩ នៅប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួន និងប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់ ជាពិសេសអាស៊ាន មានការបារម្ភកាន់តែច្រើនអំពីសំពាធបរិត្តផរណា ។ ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិកបន្តធ្លាក់ចុះ (-០,៩%) នៅត្រីមាសទី២ ។ តម្រូវការក្នុងស្រុកដែលធ្លាក់ចុះធ្ងន់ធ្ងរ ដោយសារសេដ្ឋកិច្ចធ្លាក់ចុះ បានធ្វើឱ្យទំនិញជាទូទៅធ្លាក់ថ្លៃខ្លាំងនៅសហរដ្ឋអាមេរិក ។ នៅត្រីមាសដដែល ថ្លៃទំនិញប្រើប្រាស់ជាទូទៅនៅតំបន់អឺរ៉ូ នៅថេរ ដោយសារប្រេង និងផលិតផលផ្សេងៗធ្លាក់ថ្លៃ ។ អតិផរណាថ្លៃទំនិញប្រើប្រាស់នៅជប៉ុនធ្លាក់ចុះដល់ -១,០% នៅពេលសេដ្ឋកិច្ចងើបឡើងវិញ ។ បរិត្តផរណានេះអាចមកពីសេដ្ឋកិច្ចធ្លាក់ចុះធ្ងន់ធ្ងរ និងកំណើនគម្លាតក្នុងផលិតកម្ម ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ប្រាក់ដុល្លារUS ឡើងថ្លៃទល់នឹងប្រាក់យ៉េនជប៉ុន ដោយប្ដូរបាន ៩៥,៩៥យ៉េន/ដុល្លារUS ប៉ុន្តែធ្លាក់ថ្លៃទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង ដុល្លារតៃវ៉ាន់ និងប្រាក់អឺរ៉ូ ដោយប្ដូរបាន ១២៧៣,៩វ៉ុន/ដុល្លារUS ៣៣,១ដុល្លារតៃវ៉ាន់/ដុល្លារUS និង ០,៧១អឺរ៉ូ/ដុល្លារUS ។ នៅត្រីមាសដដែល ប្រាក់ដុល្លារ US នៅថេរធៀបនឹងប្រាក់យ៉ុនចិន និងដុល្លារហុងកុង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី២ នេះ ក៏មានការធ្លាក់ថ្លៃទំនិញកសិកម្មមួយចំនួនគួរឱ្យកត់សម្គាល់ ។ ពោត (US No.2) អង្ករ (Thai 100% B) និងសណ្ដែកសៀង (US No.1) ធ្លាក់ថ្លៃ ៦,៥% ៤,៣% និង ៣,៣% រៀងគ្នា ធៀបនឹងត្រីមាសមុន ប៉ុន្តែប្រេងឆាឡើងថ្លៃ ១៣% ។ នៅទីផ្សារទំនិញថាមពល ប្រេងឆៅ សាំង និងម៉ាស៊ូតឡើងថ្លៃ ៣៥,៧% ៣៤,៨% និង ១៨,៥% រៀងគ្នា ធៀបនឹងត្រីមាសមុន ។

*រៀបរៀងដោយ សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 6.4 | 6.1 | 5.2 | 4.4 | 3.9 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 6.3 | 4.7 | 0.1 | -6.2 | -3.9 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | 1.9 | -0.6 | -4.2 | -10.1 | -3.5 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | 5.3 | 3.9 | -4.3 | -7.1 | -4.9 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 10.1 | 9.0 | 6.8 | 6.1 | 7.9 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | 4.2 | 1.7 | -2.5 | -7.8 | -3.8 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 4.8 | 3.8 | -3.6 | -4.4 | -2.2 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | 4.3 | -1.0 | -8.4 | -10.2 | -7.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | 1.4 | 0.6 | -1.3 | -2.5 | -4.8 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | 1.0 | -0.5 | -4.6 | -9.1 | 0.6 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | 2.8 | -0.5 | -6.3 | -2.6 | -3.9 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 24.9 | 21.7 | 15.7 | 4.3 | -4.8 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 10.1 | 11.9 | 11.4 | 8.5 | 5.6 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 4.8 | 8.4 | 5.9 | 3.7 | 1.3 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 7.5 | 6.5 | 5.5 | 2.1 | -0.5 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 7.7 | 7.2 | 2.2 | -0.2 | -2.8 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 24.4 | 29.0 | 23.6 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 7.8 | 5.3 | 2.5 | -0.6 | 1.5 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 5.7 | 4.6 | 2.3 | 1.7 | -0.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 4.8 | 5.5 | 4.5 | 3.9 | 2.8 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 4.2 | 4.5 | 1.9 | 0.0 | -0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 3.8 | 3.8 | 2.3 | 1.0 | 0.9 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 1.4 | 2.2 | 1.0 | -0.1 | -1.0 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 4.4 | 5.3 | 1.5 | -0.2 | -0.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.3 | 4092.5 | 4103.2 | 4062.7 | 4054.2 | 4030.3 | 4117.4 | 4089.8 | 4108.0 | 4128.55 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938 | 9705 | 9134 | 9419 | 9699.0 | 9,265.3 | 9,216.3 | 11,060 | 11,630.8 | 10,225.0 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.79 | 3.67 | 3.31 | 3.34 | 3.21 | 3.37 | 3.56 | 3.63 | 3.52 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.37 | 1.43 | 1.49 | 1.51 | 1.45 |
| ថៃ (បាត) | 40.2 | 40.2 | 37.9 | 32.22 | 33.36 | 32.25 | 34.0 | 34.83 | 35.29 | 33.98 |
| វៀតណាម (ដុង) | 15,777 | 15,859 | 15,994 | 16,030 | 16,382 | 16,881 | 16,517 | 16,537 | 16,954 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.96 | 6.82 | 6.83 | 6.84 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.8 | 7.78 | 7.80 | 7.77 | 7.75 | 7.75 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145 | 1024 | 955 | 929.04 | 1137.23 | 1018.84 | 1207.0 | 1,367.2 | 1,412.5 | 1,273.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.6 | 32.1 | 32.5 | 32.85 | 31.54 | 30.45 | 31.20 | 33.0 | 34.0 | 33.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.7 | 0.84 | 0.64 | 0.71 | 1.32 | 0.76 | 0.71 |
| ជប៉ុន (យ៉េន) | 108.2 | 110.2 | 116.4 | 117.8 | 102.46 | 104.53 | 104.03 | 96.1 | 93.72 | 95.95 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 238.03 | 254.99 | 181.22 | 183.12 | 171.16 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 1086.89 | 949.03 | 564.50 | 636.53 | 719.35 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 839.58 | 657.88 | 519.41 | 522.13 | 499.45 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 479.97 | 529.30 | 382.72 | 434.40 | 420.10 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 33.5 | 50.14 | 61.58 | 69.25 | 95.44 | 117.48 | 115.30 | 55.23 | 42.34 | 57.46 |
| ស៊ាំង - US Gulf Coast (សេន/លីត្រ) | 30.9 | 42.19 | 47.70 | 53.58 | 62.22 | 80.90 | 81.27 | 34.52 | 31.97 | 43.11 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.2 | 95.37 | 88.46 | 46.98 | 34.17 | 40.51 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

អនុមតិគំរោងវិនិយោគ បានធ្លាក់ចុះអស់ ៣ត្រីមាស បន្តបន្ទាប់ ។ នៅត្រីមាសទី២ ឆ្នាំ២០០៩ អនុមតិគំរោងវិនិយោគធ្លាក់ចុះយ៉ាងខ្លាំងអស់ ៩៦% មកត្រឹម ៣៩,៤លានដុល្លារអាមេរិក ដោយសារការធ្លាក់ចុះខ្លាំងនៃអនុមតិគំរោងវិនិយោគលើវិស័យទាំង៣ គឺ កសិកម្ម (ពី ១៧៥,៣លានដុល្លារកាលពីត្រីមាសមុនមកដល់សូន្យ) សេវាកម្ម (ពី ៤៩៥,៦លានដុល្លារមកដល់សូន្យ) និងឧស្សាហកម្ម (ធ្លាក់ចុះ ៨៤%) ។ ផ្ទុយទៅវិញ អនុវិស័យកាត់ដេរមានកំណើនខ្លាំង ពី ១៦៤លានដុល្លារ កាលពីត្រីមាសមុន ដល់ ៣៥,០លានដុល្លារ ដែលប្រហែលមកពីរដ្ឋាភិបាលបានផ្អាកការយកពន្ធដារលើឧស្សាហកម្មកាត់ដេរ ។ ត្រូវបានអនុម័តដែរនូវគម្រោងស្រាវជ្រាវខាងរ៉ែ និងគម្រោងសាងសង់រោងចក្រថាមពលជីវម៉ាស ដែលមានតំលៃស្មើនឹង ១១% នៃតំលៃអនុមតិគម្រោងសរុបក្នុងវិស័យឧស្សាហកម្ម ។

តំលៃអនុមតិគំរោងសាងសង់នៅរាជធានីភ្នំពេញ បានបន្តធ្លាក់ចុះខ្លាំងចាប់ពីត្រីមាសទី៤ ឆ្នាំ២០០៨ ។ នៅត្រីមាសទី២ ឆ្នាំ២០០៩ អនុមតិគំរោងសាងសង់សរុប ធ្លាក់ចុះ ៦៦% មកត្រឹម ៦២,៣លានដុល្លារ បើធៀបនឹងត្រីមាសមុន ។ អនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ២១% មកត្រឹម ៦,៧លានដុល្លារ ហើយអនុមតិគំរោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៨០% មកត្រឹម ១៨,៩លានដុល្លារ ។ ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៨ អនុមតិគំរោងសាងសង់សរុប ធ្លាក់ចុះ ៥៦% ក្នុងនោះអនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ៦២% និងអនុមតិគំរោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៦៦% ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ចំនួនភ្ញៀវបរទេសមកដល់កម្ពុជា ធ្លាក់ចុះ ២៥% ធៀបនឹងត្រីមាសមុន មកត្រឹម ៤៦៤.២៣០នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស ធ្លាក់ចុះ ៣៤% មកត្រឹម ២២១.២២១នាក់ ក្នុងនោះអាកាសយានដ្ឋានភ្នំពេញទទួលបានអ្នកដំណើរ ៥១% និងអាកាសយានដ្ឋានសៀមរាបទទួលបាន ៤៩% ។ ភ្ញៀវមកដល់តាមផ្លូវគោក ធ្លាក់ចុះ ៨,៥% មកត្រឹម ២៣២.១៦៦នាក់ ហើយភ្ញៀវមកដល់តាមផ្លូវទឹក ធ្លាក់ចុះ ៦៧% មកត្រឹម ១០.៨៤៣នាក់ ។ ភ្ញៀវមកសំរាកលំហែ ធ្លាក់ចុះ ២៩% មកត្រឹម ៣៨៩.៧៣៨នាក់ រីឯភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ១,៧% មកត្រឹម ៣៣.១៣២នាក់ ។ ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក គឺជាកត្តាចំបងនាំឱ្យមានការធ្លាក់ចុះចំនួនភ្ញៀវមកដល់ប្រទេសកម្ពុជា ។ ឆ្លើយតបនឹងបញ្ហានេះ រដ្ឋាភិបាលកំពុងប្រឹងប្រែងទាក់ទាញភ្ញៀវទេសចរ មកពីបណ្ដាប្រទេសដែលរងឥទ្ធិពលតិចពីវិបត្តិសេដ្ឋកិច្ចសាកល (រួមមាន វៀតណាម ថៃ និងឡាវ) តាមរយៈការធ្វើកំណែទំរង់នីតិវិធីចេញចូល ដើម្បីសម្រួលដល់ភ្ញៀវទាំងនោះ ។ នីតិវិធីថ្មីនេះ អនុញ្ញាតឱ្យភ្ញៀវទេសចរមកពីប្រទេសខាងលើ ប្រើប្រាស់លិខិតបើកផ្លូវ ដើម្បីចូលមកទស្សនាកំសាន្ត និងស្នាក់នៅក្នុងប្រទេសកម្ពុជាបានរយៈពេលមួយសប្ដាហ៍ ដែលកាលពីមុនបានត្រឹមបីថ្ងៃប៉ុណ្ណោះ ។ ជាលទ្ធផលនៃការសម្រួលនិតិវិធីនេះ ចំនួនភ្ញៀវទេសចរវៀតណាមមកដល់កម្ពុជាបានកើនឡើង ៤,២% រហូតដល់ ៧៥.៣៩៧នាក់ ហើយភ្ញៀវទេសចរឡាវ កើន ១៣% ដល់ ២៧.៩០៧នាក់ ប៉ុន្តែភ្ញៀវទេសចរថៃ ធ្លាក់ចុះ ៧,៥% មកត្រឹម ២៤.៤៤៦នាក់ ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ឱនភាពពាណិជ្ជកម្មមានសភាពកាន់តែអាក្រក់ដោយឡើងដល់ ៦២៧,៣លានដុល្លារ ធៀបនឹង ១៥៧,៦លានដុល្លារនៅត្រីមាសមុន ។ ការធ្លាក់ចុះនេះ បណ្ដាលមកពីការនាំចេញធ្លាក់ចុះខ្លាំង ខណៈពេលដែលការនាំចូលកើនឡើងតិចតួច ។ ធៀបនឹងត្រីមាសមុន ការនាំចេញសរុប ធ្លាក់ចុះ ៤០% មកត្រឹម ៤៣៣,៥លានដុល្លារ ដោយសារការនាំចេញសំលៀកបំពាក់ ត្រី និងកៅស៊ូ ធ្លាក់ចុះ ។ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះ ៣៨% មកត្រឹម ៣៧៧,៣លានដុល្លារ ឯការនាំចេញត្រី ធ្លាក់ចុះ ១៥% មកត្រឹម ០,៧លានដុល្លារ ហើយការនាំចេញកៅស៊ូ ធ្លាក់ចុះ ៣០% មកត្រឹម ៨,២លានដុល្លារ ។ ផ្ទុយទៅវិញ ការនាំចេញឈើបានកើនពី ០,០៥លានដុល្លារ រហូតដល់ ០,១លានដុល្លារ ។

នៅត្រីមាសទី២ នេះដែរ តំលៃការនាំចូលកើនឡើង ៧,៤% រហូតដល់ ១០៦០,៨លានដុល្លារ ។ ការនាំចូលផលិតផលប្រេងកាត កើន ៧,២% រហូតដល់ ៧២,២លានដុល្លារ ប៉ុន្តែការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ២៥% មកត្រឹម ៣០,៩លានដុល្លារ ក្នុងនោះការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១៥% មកត្រឹម ៩,២លានដុល្លារ និងដែកថែប ធ្លាក់ចុះ ៤៣% មកត្រឹម ១២,៥លានដុល្លារ ។ ការនាំចូលវាយនភ័ណ្ឌ ធ្លាក់ចុះ ៦៧% មកត្រឹម ១៧,៩លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឆ្នាំ២០០៩ ឱនភាពថវិកា បានថយចុះ ៦,៥% មកត្រឹម ៥១៣,៤ពាន់លានរៀល ដោយមានកំណើនទាំងផ្នែកចំណូល និងផ្នែកចំណាយ ។ ប្រាក់ចំណូលប្រមូលបាន កើន ១៤% ដល់ ១២៥២,៧ពាន់លានរៀល ក្នុងនោះចំណូលពន្ធ កើន ១៦% ដល់ ១០៩៦,៥ពាន់លានរៀល តែត្រូវប៉ះប៉ូវនឹងចំណូលមិនមែនពន្ធ ដែលធ្លាក់ចុះ ០,៧% មកត្រឹម ១៤៩,២ពាន់លានរៀល ។ ពន្ធក្នុងស្រុក មាន ៧៦% នៃចំណូលពន្ធសរុប ឬកើន ១៨% ធៀបនឹងត្រីមាសមុន ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ កើន ៩,៦% ដល់ ២៥៧,៨ពាន់លានរៀល ។ ក្នុងចំណូលមិនមែនពន្ធ ចំណូលបានពីអចលនទ្រព្យ ធ្លាក់ចុះ ២៦% មកត្រឹម ៩,៧ពាន់លានរៀល រីឯការលក់ទំនិញ និងសេវាកើន ៧,៩% ដល់ ១០០,៩ពាន់លានរៀល ។ ទន្ទឹមនឹងនេះ ចំណូលមូលធនកើន ៧៤% ដល់ ៧,០ពាន់លានរៀល ។

នៅត្រីមាសទី២ ចំណាយសរុប កើន ៧,០% ធៀបនឹងត្រីមាសមុន ដល់ ១៧៦៦,១ពាន់លានរៀល ។ ចំណាយចរន្ត កើន ៤២% ដល់ ១០៦៤,៧ពាន់លានរៀល ប៉ុន្តែត្រូវបានប៉ះប៉ូវខ្លះវិញ ដោយការថយចុះចំណាយមូលធន ១៣% មកត្រឹម ៦០៧,១ពាន់លានរៀល ។ ចំណាយលើបៀវត្សរ៍ កើន ៥៨% ដល់ ៥១៥,៥ពាន់លានរៀល ស្របពេលដែលចំណាយឧបត្ថម្ភធន និងជំនួយឧបត្ថម្ភសង្គម ធ្លាក់ចុះ ១៥% មកត្រឹម ១៨៥,៩ពាន់លានរៀល ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## អតិផរណា និងអត្រាប្តូរប្រាក់

នៅរាជធានីភ្នំពេញ ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅ ធ្លាក់ចុះ ៤,៨% ពីមួយឆ្នាំទៅមួយឆ្នាំ។ អាហារ និងភេសជ្ជៈគ្មានជាតិស្រា ធ្លាក់ថ្លៃ ៥,២% ។ ថ្លៃស្នាក់នៅ និងទឹកភ្លើង ថយចុះ ៩,៣% ថ្លៃដឹកជញ្ជូន ថយ ១៦,៥% ហើយថ្លៃទូរគមនាគមន៍ ថយ ១០,១% ។ ចំណែកឯ ថ្លៃសំលៀកបំពាក់ និងគ្រឿងសំរាប់ពាក់នៅជើង កើន ៥,១% ថ្លៃសង្ហារឹម និងប្រតិបត្តិការក្នុងផ្ទះ កើន ៥,៦% ថ្លៃថែទាំសុខភាពកើន ៣,៧% ថ្លៃសកម្មភាពលំហែកំសាន្ត កើន ០,៩% និងថ្លៃអប់រំកើន ២៦,១% ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ប្រាក់រៀលប្តូរបាន ៤១២៨,៦រៀល/ដុល្លារ US ឬធ្លាក់ថ្លៃ ២,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ប្រាក់រៀលឡើងថ្លៃ ៤,៩% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១១៩,២រៀល/បាត និងឡើងថ្លៃ ៦,៣% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ២៣,៣រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែមិថុនា ២០០៩ រូបិយវត្ថុទូទៅ (M2) កើន ៩,១% ដល់ ១៣.៨៥៩,៦ពាន់លានរៀល ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ប្រាក់រៀលចរាចរ កើន ១១% ដល់ ២៦០៣,៦ពាន់លានរៀល ។ បញ្ញើជាប្រាក់រៀលកើន ២៥% ដល់ ៣៣៤,៤ពាន់លានរៀល ហើយបញ្ញើជាដុល្លារកើន ៨,៣% ដល់ ១០.៩២១,៦ពាន់លានរៀល ។

ក្នុងអំឡុងខែមិថុនា នេះដែរ តាមការកាត់កងគ្នារវាងឥណទានសុទ្ធដល់រដ្ឋាភិបាល និងឥណទានដល់វិស័យឯកជន គេឃើញថាទ្រព្យសកម្មក្នុងស្រុក កើនបាន ១១% ដល់ ៧២៤០,៦ពាន់លានរៀល ។ ឥណទានសុទ្ធដល់រដ្ឋាភិបាលថយចុះមកត្រឹម -២៨៨៨,៩ពាន់លានរៀល ដោយសារបញ្ញើរបស់រដ្ឋាភិបាលកើនឡើង ៧,១% ដល់ ៣១៥៩,៤ពាន់លានរៀល ខណៈពេលដែលឥណទានស្ថិតនៅថេរត្រឹម ២៧០,៥ពាន់លានរៀល ។ ទន្ទឹមនឹងនេះ ឥណទានដល់វិស័យឯកជន កើន ៦,៧% ដល់ ១០.១២៩,៦ពាន់លានរៀល ។ បំណុលផ្សេងៗ កើន ១៦% ដល់ ៥៩៩១,៩ពាន់លានរៀល ដែលធ្វើឱ្យទ្រព្យសកម្មក្នុងស្រុកសុទ្ធថយចុះ៧,២% មកត្រឹម១២៤៨,៧ពាន់លានរៀល ។ ផ្ទុយទៅវិញ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១១% ដល់ ១២.៦១០,៩ ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

អង្កេតលើពលករងាយរងគ្រោះក្នុងខែសីហា ២០០៩ បង្ហាញថាប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពួកគេ បានធ្លាក់ចុះ ៨,៩% ធៀបនឹងខែឧសភា ២០០៩ ប៉ុន្តែបានកើន ២,៧% បើធៀបនឹងខែកុម្ភៈ ឆ្នាំដដែល ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ១១,៣% បើធៀបនឹងខែឧសភា ដោយធ្លាក់ពី ៨៨៩៦រៀល/ថ្ងៃ មកត្រឹម ៧៦៩២រៀល/ថ្ងៃ ។ អ្នកធាក់ស៊ីក្លូ ៨០,៦% បានប្រាប់ថា ពួកគេមិនសូវមានការងារធ្វើច្រើនដូចកាលពីប៉ុន្មានខែមុនឡើយ ជាពិសេសនៅពេលដែលចំនួនអ្នករត់ម៉ូតូឌុបបានកើនឡើង ។ អ្នកធាក់ស៊ីក្លូភាគច្រើនជាអ្នកធ្វើចំណាកស្រុកមកពីទីជនបទ ក្នុងនោះមាន ៣២,៥% បានចាកចេញមកដោយសារមិនអាចរកការងារធ្វើបាននៅក្នុងភូមិ, ២៥% ចាកចេញមកដោយសារមានជីវភាពគ្រួសារក្រីក្រ, ២២,៥% ធ្វើចំណាកស្រុក តាមរដូវកាល និង ២០% ទៀត ចាកចេញដោយសារគិតថានៅទីក្រុងសំបូរការងារធ្វើជាង ។

នៅខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ថយចុះ ១៩,៧% ធៀបនឹងខែឧសភា គឺធ្លាក់ចុះពី ១២.១៤៨រៀល/ថ្ងៃ មកត្រឹម ៩៧៥៩រៀល/ថ្ងៃ ។ ក្នុងអំឡុងពេលបីខែមុននេះ ពួកគេមិនសូវមានឱកាសច្រើន ដើម្បីរកប្រាក់ឡើយ ហើយក្នុងនោះមាន ៧៧,៥% អាចរកប្រាក់បានត្រឹមគ្រប់គ្រាន់ល្មមសំរាប់ខ្លួនឯងប៉ុណ្ណោះ ។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ ៥២,៥% ប្រាប់ថាពួកគេបានទៅខ្ចីបុលអ្នកដទៃ ដើម្បីដោះស្រាយជីវភាពនៅពេលប្រាក់ចំណូលធ្លាក់ចុះនេះ ។

នៅខែសីហានេះដែរ ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១១,២% ធៀបនឹងខែឧសភា មកត្រឹម ១២.១៥៥រៀល ។ ប៉ុន្តែបើធៀបនឹងខែកុម្ភៈ ប្រាក់ចំណូលរបស់ពួកគេកើនឡើង ៣,៣% ។ ការថយចុះនៃប្រាក់ចំណូលនេះ បណ្តាលមកពីកំណើនការប្រកួតប្រជែងរវាងកម្មករ ។ កម្មករសំណង់ភាគច្រើន (៦៥%) ប្រាប់ថា ពួកគេស្នាក់នៅក្នុងការដ្ឋានសំណង់ ហើយ ១៧,៥% ស្នាក់នៅផ្ទះជួល និង ១០% ស្នាក់នៅផ្ទះរបស់ខ្លួនឯង រីឯ ៧,៥% ទៀត ស្នាក់នៅជាមួយសាច់ញាតិ ឬនៅវត្ត ។ ពួកគេចំណាយប្រហែល ៣៦៥០រៀល/ថ្ងៃ លើម្ហូបអាហារ ឬចំណាយតិចជាងមុន ៤,៣% បើធៀបនឹងខែឧសភា ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាច ធ្លាក់ចុះ ១៣,១% បើធៀបនឹងខែឧសភា ឆ្នាំដដែល មកត្រឹម ៨៤៨៩រៀល ។ មានអ្នកលក់បន្លែដែលបានសម្ភាសតែ ១០% ប៉ុណ្ណោះដែលប្រាប់ថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ខ្លួនកើនឡើង ខណៈពេលដែលអ្នកលក់បន្លែ ៩០% ទៀត ឆ្លើយថាប្រាក់ចំណូលប្រចាំថ្ងៃ របស់ខ្លួនមាននិន្នាការផ្ទុយពីនេះ ។អ្នកលក់បន្លែភាគច្រើនបានឱ្យដឹងថា ការថយចុះប្រាក់ចំណូលបណ្តាលមកពីកំណើនការប្រកួតប្រជែងក្នុងអាជីវកម្មនេះ ដែលធ្វើឱ្យអាជីវករ ៣០% ក្លាយជាអ្នកជាប់បំណុលគេ ។ អាជីវករ ៧០% ប្រាប់ថា កង្វះដើមទុនវិនិយោគ គឺជាកត្តាមួយដែលនាំឱ្យប្រាក់ចំណូលធ្លាក់ចុះ ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលរបស់អ្នករើសអេតចាយ កើន ៨,៩% បើធៀបនឹងខែឧសភា ។ អ្នកផ្តល់សម្ភាសន៍ ៩៧,៥% ប្រាប់ថា មូលហេតុចំបងនៃកំណើននេះ គឺរបស់អេតចាយបានឡើងថ្លៃ ។ អ្នករើសអេតចាយភាគច្រើន ត្អូញត្អែរពីបញ្ហាចំងាយផ្លូវឆ្ងាយជាងមុនទៅដល់កន្លែងចាក់សំរាមនៅជើងឯក ដែលធ្វើឱ្យពួកគេត្រូវចំណាយពេលវេលា និងសោហ៊ុយច្រើនជាងមុន ដើម្បីទៅប្រមូលរបស់អេតចាយនៅទីនោះ ។ ពួកគេត្រូវចំណាយប្រាក់ ៣០០០រៀល/ថ្ងៃ សំរាប់ថ្លៃដឹកជញ្ជូន ហើយនេះជាតួលេខចំណាយធំមួយ បើធៀបនឹងចំណូលប្រចាំថ្ងៃរបស់ពួកគេ ។ អ្នករើសអេតចាយ ៨៥% ប្រាប់ថា ពួកគេត្រូវប្រើប្រាក់ចំណូលរបស់ខ្លួន ដើម្បីជួលផ្ទះស្នាក់នៅ ។

*រៀបរៀងដោយ*

*ផាន់ ដាលីស និង ប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 12.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 | 175.3 | 0.0 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 187.2 | 328.0 | 52.9 | 95.0 | 91.6 | 485.4 | 257.7 | 39.4 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *40.7* | *69.1* | *42.3* | *47.8* | *31.3* | *21.4* | *16.4* | *35.0* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 | 495.6 | 0.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* | *254.1* | *0.0* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 | 928.6 | 39.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 504.7 | -35.9 | -78.1 | 1548.2 | 9.2 | -65.3 | -41.2 | -95.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 | 266.5 | -99.0 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 21.7 | 20.2 | 45.3 | 17.6 | 52.1 | 39.7 | 32.1 | 6.7 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 117.5 | 57.6 | 40.9 | 55.1 | 65.6 | 60.0 | 95.2 | 18.9 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 | 252.2 | 53.7 | 36.7 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 179.7 | 172.2 | 137.3 | 140.9 | 486.9 | 351.9 | 181.1 | 62.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 24.2 | -4.2 | -1.4 | 2.6 | 245.6 | -27.7 | -48.5 | -65.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 88.2 | 120.2 | -1.4 | -2.6 | 170.9 | 104.4 | 31.9 | -55.8 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 278.5 | 368.8 | 402.0 | 262.0 | 259.2 | 316.2 | 335.2 | 221.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 | 261.4 | 287.1 | 243.0 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 431.8 | 608.0 | 644.2 | 454.0 | 445.5 | 577.6 | 622.3 | 464.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 1.7 | 40.8 | 6.0 | -29.5 | -1.9 | 29.6 | 7.7 | -25.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 16.5 | 17.8 | 17.0 | 6.9 | 3.2 | -5.0 | -3.4 | 2.2 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 890.8 | 793.4 | 803.1 | 539.6 | 928.7 | 728.6 | 721.4 | 433.5 |
| ក្នុងនេះ: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 846.1 | 727.1 | 773.4 | 463.8 | 868.8 | 678.8 | 606.9 | 377.3 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 11.7 | 14.6 | 7.0 | 11.0 | 12.9 | 5.2 | 11.8 | 8.2 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.1 | 0.1 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 1.2 | 0.9 | 0.7 | 0.3 | 0.6 | 0.6 | 0.9 | 0.7 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 | 987.7 | 1060.8 |
| ក្នុងនេះ: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 | 62.9 | 67.3 | 72.2 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 154.4 | 34.9 | 32.5 | 39.7 | 40.7 | 35.6 | 29.9 | 41.4 | 30.9 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 | 879.0 | 957.7 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 | -187.7 | -157.6 | -627.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | 22.9 | -14.1 | 6.4 | -40.0 | 87.3 | -21.9 | -10.5 | -37.8 |
| ការនាំចេញសរុប | - | - | - | - | 26.4 | -10.9 | 1.2 | -32.8 | 72.1 | -21.5 | -0.9 | -39.9 |
| ការនាំចូលសរុប | - | - | - | - | 1.4 | 6.3 | 0.1 | 19.8 | -12.8 | -10.8 | 7.8 | 7.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 | -6.6 | -21.5 | -18.6 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 | -8.2 | -10.2 | -19.7 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 | -6.8 | 0.4 | -9.9 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៩ ( ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 | 1101.7 | 1252.7 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 | 1097.7 | 1245.7 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 | 947.4 | 1096.5 |
| ពន្ធក្នុងស្រុក | - | - | - | - | 584.8 | 661.8 | 719.9 | 955.5 | 776.7 | 796.3 | 712.0 | 838.7 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 259.8 | 303.5 | 258.1 | 299.5 | 294.5 | 309.4 | 235.4 | 257.8 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 186.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 | 150.3 | 149.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 14.8 | 13.6 | 2.9 | 53.9 | 11.0 | 10.2 | 13.1 | 9.7 |
| លក់ទំនិញ និងសេវា | - | - | - | - | 100.1 | 124.3 | 118.9 | 96.3 | 99.7 | 109.8 | 93.5 | 100.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 72.0 | 38.5 | 89.6 | 41.9 | 106.4 | 60.3 | 43.7 | 38.6 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 0.0 | 4.5 | 4.8 | 16.5 | 8.7 | 49.3 | 4.0 | 7.0 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 | 1650.6 | 1766.1 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 | 693.6 | 607.1 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 | 752.4 | 1064.7 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 253.4 | 362.6 | 250.7 | 367.0 | 363.6 | 415.7 | 327.4 | 515.5 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 115.0 | 194.2 | 104.3 | 325.7 | 111.9 | 385.2 | 217.3 | 185.9 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 402.6 | 325.5 | 193.1 | 403.8 | 442.6 | 345.4 | 207.7 | 363.2 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -78.7 | -543.6 | 135.0 | -281.1 | -365.8 | -495.9 | -548.9 | -513.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 290.3 | 741.5 | 299.2 | 615.8 | 435.0 | 705.1 | 507.8 | 326.7 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -148.0 | -185.8 | -294.1 | -236.5 | 234.7 | 168.9 | -310.3 | 236.5 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស ( មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ( ខែតុលា-ធ្នូ ២០០៦:១០០) | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | - | - | - | - | 7.7 | 12.3 | 20.6 | 33.3 | 28.7 | 17.8 | 4.3 | -4.8 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | 12.8 | 18.9 | 29.5 | 47.6 | 37.4 | 24.1 | 6.1 | -5.2 |
| - ដឹកជញ្ជូន | - | - | - | - | 2.3 | 9.6 | 21.7 | 28.9 | 27.8 | 4.1 | -13.0 | -16.5 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ ( តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 | 4111.6 | 4128.6 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 130.0 | 129.3 | 129.1 | 125.4 | 121.9 | 117.7 | 116.6 | 119.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 25.3 | 25.2 | 25.2 | 24.9 | 24.8 | 24.3 | 23.6 | 23.3 |
| ថ្លៃមាស ( ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 80.8 | 94.4 | 111.6 | 107.7 | 106.0 | 98.2 | 105.6 | 110.7 |
| ថ្លៃម៉ាស៊ូត ( រៀល/លីត្រ) | 1508 | 2088 | 2633 | 3140 | 3203 | 3679 | 3982 | 4975 | 5495 | 3768.9 | 2873.7 | 3056.9 |
| ថ្លៃសាំង ( រៀល/លីត្រ) | 2150 | 2833 | 3442 | 4004 | 4002 | 4368 | 4580 | 5171 | 5391 | 3861.3 | 3112.6 | 3452.4 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៩ ( តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ពាន់លានរៀល | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4,027 | 4,797 | 5,475 | 7,224 | 9,768 | 10,735 | 10,911 | 11,353 | 10,809 | 10,345 | 11,222 | 12,611 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | 140 | 576 | 1,136 | 1,345 | 1,748 | 15,13.3 | 1,266 | 1,249 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1,547 | -1,816 | -2,400 | -2,678 | -2,653 | -2,987 | -3,048 | -2,889 |
| ឥណទានដល់ផ្នែកឯកជន | 1,337 | 1,817 | 2,394 | 3,630 | 5,376 | 6,386 | 8,050 | 9,206 | 9,781 | 9,894 | 9,814 | 10,129 |
| រូបិយវត្ថុទូទៅ M2 | 3,329 | 4,330 | 5,025 | 6,942 | 9,908 | 11,311 | 12,047 | 12,698 | 12,557 | 11,858 | 12,488 | 13,859 |
| រូបិយវត្ថុ M1 | 937 | 1,153 | 1,323 | 1,658 | 1,750 | 2,052 | 2,389 | 2,467 | 2,335 | 2,399 | 2,545 | 2,695 |
| រូបិយវត្ថុផ្សេងៗ | 2,392 | 3,177 | 3,702 | 5,285 | 8,158 | 9,259 | 9,658 | 10,231 | 10,223 | 9,459 | 9,942 | 11,164 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 53.4 | 62.9 | 54.5 | 43.1 | 26.7 | 4.8 | 3.7 | 9.1 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 12.0 | 23.8 | 33.2 | 41.1 | 33.4 | 16.9 | 6.5 | 9.2 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 66.5 | 75.2 | 61.0 | 43.5 | 25.3 | 2.2 | 2.9 | 9.1 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ ( ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ ( ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន ( %) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2007 | 2008 | 2009 | | | 2009 | | |
| | | | | | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7,618 | 8,085 | 7,469 | 8,075 | 9,675 | 12,628 | 8,534 | 8,896 | 7,892 | -32.4 | 4.0 | -11.0 |
| អ្នកលីសែង | 6,925 | 6,734 | 6,545 | 8,588 | 9,119 | 9,005 | 10,476 | 10,319 | 8,321 | 16.0 | -2.0 | -19.0 |
| អ្នកលក់បន្លែតូចតាច | 6,953 | 7,739 | 6,390 | 8,220 | 8,552 | 9,926 | 7,614 | 9,764 | 8,489 | -23.0 | 28.0 | -13.0 |
| អ្នករើសអេតចាយ | 4,456 | 5,167 | 4,416 | 5,422 | 5,727 | 4,652 | 5,170 | 6,637 | 7,228 | 11.0 | 28.0 | 9.0 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4,439 | 4,344 | 4,412 | 4,482 | 4,643 | 4,327 | 4,283 | 4,346 | 4,665 | -1.0 | 1.0 | 7.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,233 | 4,370 | 5,306 | 5,516 | 6,426 | 8,697 | 7,044 | 7,126 | 5,900 | -19.0 | 1.0 | -17.0 |
| កម្មកររោងចក្រកាត់ដេរ | 8,048 | 7,359 | 7,649 | 7,568 | 7,240 | 6,554 | 6,754 | 6,691 | 7,558 | 3.0 | -1.0 | 13.0 |
| អ្នករត់ម៉ូតូឌុប | 9,259 | 10,595 | 8,201 | 10,634 | 11,872 | 15,691 | 11,655 | 12,148 | 9,759 | -26.0 | 4.0 | -20.0 |
| កម្មករសំណង់គ្មានជំនាញ | 6,391 | 6,712 | 5,918 | 6,155 | 7,777 | 8,779 | 6,115 | 9,956 | 9,632 | -30.0 | 63.0 | -3.0 |
| កម្មករសំណង់មានជំនាញ | 12,691 | 12,049 | 10,316 | 11,154 | 11,286 | 12,710 | 11,771 | 13,688 | 12,155 | -7.0 | 16.0 | -11.0 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

តពីទំព័រ ២៤ **ព័ត៌មានថ្មីៗ ...**

*កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ* (DGPSR)

កញ្ញា ធន់ វិមាលា កំពុងកែសំរួលបន្តិចបន្តួចជាចុងក្រោយ ដើម្បីបង្ហើយរបាយការណ៍សិក្សា "ការដឹកនាំនៅថ្នាក់ភូមិ/ឃុំ" ហើយក៏បានរៀបចំរួចរាល់ដែរ នូវឯកសារសង្ខេបគោលនយោបាយមួយ ផ្អែកលើរបាយការណ៍ខាងលើ ។ការសិក្សាពី"សមត្ថភាពស្រាវជ្រាវនៃសាកលវិទ្យាល័យនៅកម្ពុជា" បានចប់សព្វគ្រប់តាមផែនការ ។ ឯកសារព្រាងទី១ នៃគំរោង "អភិបាលកិច្ចថ្នាក់មូលដ្ឋានលើធនធានទ្រព្យរួម: ករណីសិក្សាពីទឹកស្រោចស្រពនៅកម្ពុជា" បានចប់រួចរាល់កាលពីចុងខែកក្កដា ហើយបច្ចុប្បន្ន អ្នកស្រី ជា ជូ កំពុងធ្វើការកែសម្រួលឯកសារនេះ ដោយមានកែតម្រូវផ្នែកខ្លះ ដកផ្នែកខ្លះចេញ និងដាក់បញ្ចូលថែមផ្នែកខ្លះទៀត ។ឯកសារព្រាងទី៥ស្ដីពីគំរោងផ្ដល់យោបល់ពិគ្រោះដល់គណៈកម្មាធិការជាតិ សំរាប់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងមហាផ្ទៃ ដែលទទួលមូលនិធិពីវិទ្យាស្ថានសិក្សាពីទីក្រុង (Urban Institute) បានរួចរាល់មួយភាគធំ ហើយសិក្ខាសាលាផ្ដល់យោបល់ពិគ្រោះមួយផ្សេងទៀត គ្រោងធ្វើឡើងនៅខែតុលានេះ ។ សំណើគំរោង "ការយល់ដឹងពីការពាក់ព័ន្ធរវាង អង្គនីតិបញ្ញត្តិសង្គម និងស៊ីវិលនៅកម្ពុជា" ត្រូវបានដាក់ជូនទាន់ពេល ដល់វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) និងកំពុងរង់ចាំទទួលយោបល់ត្រលប់ ។ សំរាប់គំរោង "ការវិភាគពីរដ្ឋកម្ពុជាៈ អំណោយផលដល់ការអភិវឌ្ឍ?" ការចុះសិក្សាដល់កន្លែង គ្រោងធ្វើឡើងនៅពាក់កណ្ដាលខែតុលា ដើម្បីយកគំនិតមួយចំនួន ដែលទទួលបានពីការសិក្សាឯកសារ ទៅប្រៀបធៀបផ្ទៀងផ្ទាត់ជាមួយការពិតជាក់ស្ដែង ។ គំរោងមួយទៀតគឺ "គ្រោងការសេវាច្រកចេញចូលតែមួយ" ក្រោមជំនួយមូលនិធិពីធនាគារពិភពលោកបានទទួលការយល់ស្រប និងបានចាប់ផ្ដើមនៅដើមខែកញ្ញា ហើយត្រូវចប់សព្វគ្រប់ក្នុងរយៈពេលកំណត់ ៥ខែ ។

*កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន*

ក្រុមអ្នកស្រាវជ្រាវនៃកម្មវិធីនេះ បានបញ្ចប់ការសំអាត និងវិភាគទិន្នន័យសំរាប់សមាសភាគសេដ្ឋកិច្ច នៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងការគ្រប់គ្រងធនធានទឹក (WRMRCDP) ។ ក្រុមស្រាវជ្រាវ ក៏បានរៀបចំវគ្គបណ្ដុះបណ្ដាលមួយ ក្រោមចំណងជើង "ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ" និងបានជួបពិភាក្សាជាមួយក្រុមអ្នកស្រាវជ្រាវ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីកសាង និងកែលំកម្មវិធីសិក្សាពីការគ្រប់គ្រងធនធានទឹក ។កម្មវិធីនេះបានរៀបចំហើយ នូវផែនការការងារឆ្នាំ២០០៩-២០១១ ។ ក្រុមការងាររបស់កម្មវិធី ក៏បានជួបជាមួយ AusAID ដើម្បីតាមដានបន្តនូវរបាយការណ៍លូតលាស់ការងារប្រចាំឆ្នាំទី៣ និងធ្វើការកែសម្រួលរបាយការណ៍នេះ ។ គំរោង "ព្រៃត្រូពិចសំរាប់កាត់បន្ថយភាពក្រីក្រ ការវិភាគទិន្នន័យពីកំរិតគ្រួសារដល់កំរិតសកល" កំពុងស្ថិតក្នុងដំណាក់កាលសំអាតទិន្នន័យ ដោយមានកិច្ចសហការជាមួយបុគ្គលិកផ្នែកគ្រប់គ្រងទិន្នន័យរបស់ CIFOR ។ ចំពោះគំរោង "ការកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប" លោក យ៉ែម ដារារដ្ឋ បានបញ្ចប់ការកែសម្រួលផែនការការងារ និងថវិកា និងបានបញ្ជូនសំណើទៅឱ្យមូលនិធិអភិវឌ្ឍន៍អាស៊ីរួចរាល់ហើយ ។ ក្រុមអ្នកស្រាវជ្រាវក្នុងកម្មវិធីនេះ ក៏បានជួបប្រជុំមួយជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សាពីផែនការការងារ និងថវិកានេះដែរ ។ សំរាប់គំរោងស្ដីពីមាត្រាមានចីរភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្រុមអ្នកស្រាវជ្រាវបានបញ្ចប់ការសំអាត និងវិភាគទិន្នន័យ ហើយកំពុងសរសេរបង្ហើយរបាយការណ៍ ។ ក្រុមអ្នកស្រាវជ្រាវក៏បានជួបជាមួយវិទ្យាស្ថានបរិស្ថានក្រុងស្តុកហុល (SEI) ដើម្បីពិភាក្សារបន្ថែមពីការសម្របសម្រួល និងកិច្ចសហការលើសកម្មភាពស្រាវជ្រាវជាច្រើនថែមទៀត ។

*កម្មវិធីអភិវឌ្ឍន៍សង្គម*

នៅខែកញ្ញានេះ ក្រុមអង្កេតបានចុះសិក្សាដល់កន្លែងទាក់ទងនឹងការសិក្សាគោលពីអ្នកគ្រប់គ្រងគន្លឹះ សំរាប់កម្មវិធីជួយទ្រទ្រង់វិស័យសុខាភិបាល ដោយបានធ្វើជាក់ស្ដែងនៅក្នុងមន្ទីរពេទ្យចំនួន ៣០ និងស្រុកប្រតិបត្តិ ៣០ ក្នុងខេត្តក្រុងចំនួន ២១ ។CDRI រួមជាមួយ វិទ្យាស្ថានគោលនយោបាយអ៊ុកស្វដ (OPI) និងដោយមានជំនួយគាំទ្រពីនាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិ (UK-DFID) គ្រោងធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទមួយស្ដីពី "វិស័យសុខាភិបាលៈ ស្ថាប័ន សន្ទុះចិត្ត និងគ្រឿងលើកទឹកចិត្ត" នៅថ្ងៃទី ២៦-២៨ មេសា ២០១០ នៅរាជធានីភ្នំពេញ ។ សន្និសីទនេះ នឹងមានការចូលរួមពីសំណាក់វាគ្មិនក្នុងប្រទេសកម្ពុជា និងមកពីបរទេស តាមរយៈកិច្ចសន្យាអនុវត្តការងារ និងលិខិតអញ្ជើញ ។សេចក្ដីប្រកាសឱ្យដាក់ស្នើឯកសារសំរាប់សន្និសីទបានចប់សព្វគ្រប់ ហើយគណៈកម្មាធិការជ្រើសរើសនៃសន្និសីទតំបន់នេះ ក៏បានធ្វើការសំរេចចិត្តរួចហើយ ផ្អែកលើអត្ថបទសង្ខេបខ្លឹមសារនានា ។ ក្នុងចំណោម ១៤ អត្ថបទសង្ខេប ដែលបញ្ជូនមកពីតំបន់ផ្សេងៗគ្នា គេបានជ្រើសរើស ៥ សំណើ ជាឯកសារចុះកិច្ចសន្យា និង ៤ សំណើ ជាឯកសារអញ្ជើញចូលរួម ។ កម្មវិធីព្រាងនៃសន្និសីទបានរៀបចំរួចរាល់ រីឯលិខិតអញ្ជើញអ្នកដឹកនាំសំរាប់វគ្គទាំង ៥ នៃសន្និសីទ ក៏បានផ្ញើចេញស្រេចបាច់ ដោយក្នុងនេះមាន ២នាក់ បានយល់ព្រមតាមការអញ្ជើញរួចហើយដែរ ។ គំរោងស្ដីពី "សុវត្ថិភាពជនក្រីក្រនៅក្រុងភ្នំពេញៈ ការសិក្សាពីបទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សា ក្នុង ៥ សហគមន៍ក្រីក្រនៅក្រុងភ្នំពេញ" បានចាប់ដំណើរការហើយ ។ ការសិក្សាឯកសារនៅការិយាល័យបានចប់សព្វគ្រប់ និងបានបញ្ជូនលទ្ធផលទៅអង្គការ UN-Habitat រួចហើយ ដើម្បីសុំយោបល់ ។ បញ្ជីសំនួរសំរាប់អង្កេតបានរៀបចំរួចរាល់ បានយកទៅប្រើសាកល្បងនៅថ្ងៃទី ១ តុលា ហើយបានធ្វើការកែសម្រួលតាមនោះហើយ ។ ឥឡូវនេះ ក្រុមអ្នកធ្វើអង្កេតកំពុងចុះប្រមូលទិន្នន័យដល់កន្លែង ។

ក្នុងអំឡុងពេលនេះដែរ ក្រុមបណ្តុះបណ្តាល បានដំណើរការចប់រួចរាល់នូវវគ្គ "ការងារកសាងសន្តិភាព" ចំនួន ៤ ដោយបានចុះដកពិសោធន៍ជាក់ស្តែងមួយលើកនៅខេត្តកំពង់ស្ពឺទៀតផង ។ ពិធីបញ្ចប់វគ្គបណ្តុះបណ្តាលមួយ បានរៀបចំឡើងនៅថ្ងៃទី ១១ កញ្ញា ដោយមានការប្រគល់វិញ្ញាបនប័ត្រដល់សិក្ខាកាមដែលបានរៀនចប់ដោយជោគជ័យនូវវគ្គ "ការងារកសាងសន្តិភាព" និង វគ្គ "បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល" ។ អ្នកស្រី ហ៊ុយ វ៉ដួល ដែលបានទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសម៉ាឡេស៊ី ស្តីពីសន្តិភាព និងការដោះស្រាយទំនាស់ ក្រោមជំនួយឧបត្ថម្ភពី Church World Service បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញហើយ ។

### *កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់*

របាយការណ៍ស្តីពី "ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីវិនិយោគចិនទៅលើធនធានធម្មជាតិនៅកម្ពុជា" កំពុងរង់ចាំយោបល់ពីម្ចាស់ជំនួយ ។ ការសិក្សាមួយផ្សេងទៀតស្តីពី "វិនិយោគចិននៅកម្ពុជា" កំពុងត្រូវបានកែសម្រួលដើម្បីបញ្ចូលនូវករណីសិក្សាចំនួន ៦ ហើយកាលពីចុងខែកញ្ញានេះ ក្រុមសិក្សាក៏បានផ្ញើរបាយការណ៍ព្រាងទី២ ជូនទៅម្ចាស់ជំនួយ (សាកលវិទ្យាល័យឈៀងម៉ៃ) ផងដែរ ។ របាយការណ៍ព្រាងលើជុំទី២ នៃ "ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា" ដែលជាការស្រាវជ្រាវរួមគ្នាមួយរវាងកម្មវិធីនេះ ហើយនិងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD) នោះ បានបញ្ជូនទៅឱ្យធនាគារពិភពលោករួចរាល់ហើយ ។ សំរាប់គំរោង "ការវាយតម្លៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃមហាអនុតំបន់មេគង្គ" ដែលអនុវត្តរួមគ្នាជាមួយ PARD ហើយនិងកម្មវិធីអភិវឌ្ឍន៍សង្គម ឯកសារបំផុសគំនិតបានបញ្ជូនទៅឱ្យម្ចាស់ជំនួយរួចរាល់ហើយការចុះអង្កេតដល់កន្លែង គ្រោងចាប់ផ្តើមនៅចុងឆ្នាំនេះ ។ អត្ថបទសង្ខេបគោលនយោបាយមួយ ស្តីពី "ផលប៉ះពាល់នៃវិត្តិសេដ្ឋកិច្ចសាកលទៅលើកម្មករកាត់ដេរ និងប្រាក់ផ្ញើទៅផ្ទះ: ករណីនៅកម្ពុជា" ដែលទទួលមូលនិធិពីUNESCAP ត្រូវបានបញ្ជូនទៅម្ចាស់ជំនួយរួចរាល់ ហើយអត្ថបទសង្ខេបគោលនយោបាយ ស្តីពី "ផលប៉ះពាល់ខាងសង្គមកិច្ចនៃការរួមចុះសេដ្ឋកិច្ចសាកលទៅលើកម្ពុជា និងទៅលើភាពក្រីក្រនៅក្នុងប្រទេស" កំពុងកែសម្រួលឡើងវិញ ដើម្បីដាក់បញ្ចូលមតិយោបល់ ដែលទទួលបានពីអ្នកចូលរួមមកពីជាង ២០០ប្រទេស ក្នុងពេលធ្វើសន្និសីទនៅទីក្រុងហាណូយ ។ ជុំទី២ នៃការសិក្សាអំពី "ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល" ដែលទទួលមូលនិធិពីវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេសកំពុងជឿនលឿនទៅមុខយ៉ាងល្អ ។

កាលពីថ្ងៃទី ៧-៨ តុលា ២០០៩ បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដោយសហការណ៍ជាមួយ CDRI បានដំណើរការសន្និសីទផ្សព្វផ្សាយថ្នាក់តំបន់មួយ ស្តីពីការសិក្សា DAN ចំនួនពីរ គឺ "ផលប្រយោជន៍ និងចំណាយសេដ្ឋកិច្ច នៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ និង "ពាណិជ្ជកម្ម កសិកម្ម ក្នុងមហាអនុតំបន់មេគង្គ" នៅសណ្ឋាគារភ្នំពេញ ក្រុងភ្នំពេញ ។ ការសិក្សាទាំងពីរនេះ ជាការងារសហការគ្នារវាងបណ្ឌិត្យវិទ្យាស្ថានស្រាវជ្រាវឈានមុខនៅប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និង ខេត្តយុនណាន់ប្រទេសចិន ក្រោមជំនួយគាំទ្រពីមូលនិធិ Rockfeller ។ សន្និសីទរយៈពេលពីរថ្ងៃនេះ បានទាក់ទាញភ្ញៀវមកចូលរួម ២៣៥នាក់ដែលមានជាអាទិ អ្នកកសាងគោលនយោបាយ ម្ចាស់ជំនួយ និងសង្គមស៊ីវិល និងដែលផ្តល់ការពិភាក្សា និងព័ត៌មានត្រឡប់សំខាន់ៗជាច្រើន ។

កាលពីថ្ងៃទី ០៩-១០ កញ្ញា ២០០៩ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ឆ្នាំ២០០៩ស្តីពី "ការរួមចំណែកនៃការស្រាវជ្រាវ ចំពោះគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" បានប្រារព្ធធ្វើឡើងនៅសណ្ឋាគារកាំបូឌីយ៉ាណា ដោយទទួលបានជំនួយគាំទ្រពីវិទ្យាស្ថាន IDRC ។ សន្និសីទនេះ មានបញ្ចូលបទបង្ហាញប្រកបដោយគុណភាពខ្ពស់លើ ៤ ប្រធានបទ គឺ (១) កសិកម្ម ធនធានធម្មជាតិ និងការចិញ្ចឹមជីវិតនៅជនបទក្នុងអន្តរកាល (២) សារៈសំខាន់នៃ ការអភិវឌ្ឍសេដ្ឋកិច្ចមានមូលដ្ឋានធំទូលាយ (៣) ការលើកកំពស់ការអភិវឌ្ឍសង្គមប្រកបដោយសមធម៌ និង (៤) ការពង្រឹងអភិបាលកិច្ចល្អ ។ សន្និសីទឆ្នាំនេះ សម្រេចបានជោគជ័យធំធេងដោយទទួលបានការចូលរួមយ៉ាងច្រើន និងការពេញចិត្តពីសំណាក់អ្នកចូលរួមទាំងឡាយ ដែលរួមមានរដ្ឋាភិបាល សហគមន៍ម្ចាស់ជំនួយ វិទ្យាស្ថានស្រាវជ្រាវនានា អង្គការមិនមែនរដ្ឋាភិបាល និងមជ្ឈដ្ឋានសិក្សា ។ អង្កេតវាយតម្លៃនៅចុងរបៀបវារៈបានឱ្យដឹងថា អ្នកចូលរួមភាគច្រើនមានការពេញចិត្តនឹងសន្និសីទនេះ ហើយមានបំណងចូលរួមកម្មវិធីនេះទៀតនៅឆ្នាំក្រោយ ដោយពួកគេយល់ថា កម្មវិធីនេះជាវេទិកាដ៏មានប្រយោជន៍សំរាប់ចែករំលែកព័ត៌មាន ទទួលបានចំណេះដឹងថ្មីៗពីការស្រាវជ្រាវអភិវឌ្ឍន៍ និងបង្កើតបណ្តាញទំនាក់ទំនង ។

### *កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ*

CDRI និងអង្គការ WorldFish Center បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងលើគំរោងមួយ សំដៅកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប ។ ការចុះសិក្សាដល់កន្លែងលើកទីមួយបានធ្វើឡើងនៅថ្ងៃទី ៥-១៥ តុលា ។ គំរោង "ការវាយតម្លៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃមហាអនុតំបន់មេគង្គ" សំរាប់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងដំណើរការទៅមុខ ហើយសេចក្តីព្រាងឯកសារបំផុសគំនិត បានបញ្ជូនទៅ ADB រួចរាល់ហើយ ដើម្បីសុំយោបល់ត្រលប់ ។

តាំងពីឆ្នាំ២០០៧ មក CDRI បានរៀបចំយ៉ាងទៀងទាត់ ក្នុងពីរខែម្តងនូវសិក្ខាសាលាស្រាវជ្រាវស្តីពីបញ្ហាផ្សេងៗខាងអភិវឌ្ឍន៍ ក្នុងគោលដៅចែករំលែកលទ្ធផលស្រាវជ្រាវ ពង្រឹងគុណភាពស្រាវជ្រាវ កែលំអវិធីសាស្ត្រស្រាវជ្រាវ កសាងនូវគោលគំនិត និងធ្វើវិភាគលើប្រធានបទស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្សាសាលាទាំងនេះមានមកពី CDRI ព្រមទាំងស្ថាប័ន និង NGOs នានានៅក្រុងភ្នំពេញ ។ សំរាប់សិក្ខាសាលានៅអំឡុងពេលនេះ អ្នកធ្វើបទបង្ហាញរបស់ CDRI មាន លោក ហ៊ីង វុត្ថា និង លោក ដួង វីរ័ត្ន រីឯអ្នកធ្វើបទបង្ហាញមកពីខាងក្រៅមាន សាស្ត្រាចារ្យ Sorpong Peou មកពីសាកលវិទ្យាល័យ Sophia University នៅប្រទេសជប៉ុន និង លោក Mith Samonn អ្នកវិភាគស្រាវជ្រាវនៅអង្គការ WorldFish Center ។ ប្រធានបទនានារួមមាន ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្មនិងធនធានធម្មជាតិ និងកសិកម្ម ។

# ព័ត៌មានថ្មីៗពី
# វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បន្តចូលរួមចំណែកក្នុងសន្និសីទ និងកិច្ចប្រជុំជាន់ខ្ពស់ថ្នាក់តំបន់ និងអន្តរជាតិស្ដីពីផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចក្នុងតំបន់ និងជាសាកល និងអនាគតនៃសមាហរណកម្មថ្នាក់តំបន់ នៅអាស៊ីខាងកើត ។ ក្នុងខែតុលា នាយកប្រតិបត្តិនៃ វបសអ បានចូលរួមក្នុងការប្រជុំប្រចាំឆ្នាំនៃវេទិកាវិទ្យាស្ថាននៅអាស៊ីខាងកើត ដែលរៀបចំឡើងដោយវិទ្យាស្ថានកូរ៉េ សម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ ។ វេទិកាជាអន្តរជាតិឆ្នាំនេះ មានប្រធានបទថា "ឆ្ពោះទៅរកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាស៊ីខាងកើត: ជម្រើស និងសកម្មភាពនាពេលអនាគត" នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ។

នាយកប្រតិបត្តិរបស់វិទ្យាស្ថាន ក៏បានទៅចូលរួមសន្និសីទអន្តរជាតិរបស់អាស៊ាន + ៣ ដែលរៀបចំឡើងដោយគណៈកម្មាធិការកំណែទម្រង់ និងកិច្ចការអភិវឌ្ឍន៍ជាតិ នៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចរបស់ប្រទេសចិន ។ សន្និសីទនេះ មានប្រធានបទថា "សេដ្ឋកិច្ចអាស៊ីខាងកើត: វិបត្តិ ការងើបឡើងវិញ និងគោលនយោបាយឆ្លើយតប "ដែលប្រារព្ធធ្វើឡើងនៅទីក្រុងប៉េកាំង ។ លោកនាយក បានធ្វើបទបង្ហាញជារបាយការណ៍ស្ដីពីប្រទេសកម្ពុជា ដែលមានបញ្ចូលព័ត៌មានថ្មីៗពីការស្រាវជ្រាវ របស់ វបសអ និងការស្រាវជ្រាវផ្សេងទៀត ព្រមទាំងអនុសាសន៍ខាងគោលនយោបាយពាក់ព័ន្ធនឹងផលប៉ះពាល់នៃវិបត្តិ ហើយនិងយុទ្ធសាស្ត្រ សម្រាប់ធ្វើឱ្យប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចឡើងវិញ និងមានការអភិវឌ្ឍប្រកបដោយចីរភាព ។ សន្និសីទនៅទីក្រុងប៉េកាំង ក៏បានបង្កើតនូវបណ្ដាញស្រាវជ្រាវខាងគោលនយោបាយ និងអ្នកព្យាករណ៍ផ្លូវការនៅអាស៊ីខាងកើត ដែល វបសអ នឹងចូលរួមជាសមាជិកដែរ ។

នៅខែវិច្ឆិកា វបសអ នឹងរួមសហការជាមួយសមាគមសេដ្ឋកិច្ចកម្ពុជា ដើម្បីរៀបចំសន្និសីទប្រចាំឆ្នាំលើកទី៣៤ របស់សហព័ន្ធសមាគមសេដ្ឋកិច្ចអាស៊ាន ។ សន្និសីទនេះ មានប្រធានបទថា "ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកលទៅលើបណ្ដាប្រទេសអាស៊ាន និងវិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់ទៅលើប្រជាជនក្រីក្រ" ។

នៅដើមខែធ្នូ វបសអ នឹងសម្រាកដកឃ្លាទៅប្រជុំថ្នាក់គ្រប់គ្រង-បុគ្គលិកប្រចាំឆ្នាំរយៈពេលពីរថ្ងៃនៅខេត្តកោះកុងដើម្បីឆ្លុះបញ្ចាំងលើមេរៀននៃសមិទ្ធផលដែលទទួលបានក្នុងឆ្នាំ២០០៩ អាទិភាពសម្រាប់ឆ្នាំ២០១០ និងការស្រាវជ្រាវសំខាន់ៗ ព្រមទាំងគោលនយោបាយដែលគួរដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រស្រាវជ្រាវពីប្រទេសកម្ពុជា របស់ វបសអ ។ យុទ្ធសាស្ត្រនេះនឹងក្លាយជាក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥ របស់ វបសអ ។

## ផ្នែកស្រាវជ្រាវ

ពីខែតុលា ដល់ ខែធ្នូ ២០០៩ CDRI អនុវត្តសកម្មភាពស្រាវជ្រាវមួយចំនួនដែលមានជាសង្ខេបដូចតទៅ:

(តទៅទំព័រ ២២)

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៩

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@wicam.com.kh

website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ

កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា

ជំនួយការកែសំរួល: វ៉ា វណ្ណៈ និង ខេង សេង

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៩ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនះរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ឱ្យដោយឥតគិតថ្លៃតាមរយៈវេបសាយ: http://www.cdri.org.kh